# សេវាកម្មជំនួយផ្នែកច្បាប់នៅប្រទេសកម្ពុជា

## របាយការណ៍នៃការស្ទង់មតិនៅក្នុងចំណោមអ្នកផ្តល់សេវាកម្មជំនួយផ្នែកច្បាប់

*Christoph Sperfeldt/ ហ៊ុង ដានី / Daniel Hong*

គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC)

ខែវិច្ឆិកា ឆ្នាំ២០១០

# មាតិកា

អក្សរកាត់.........................................................................................................................................២

១-សេចក្តីផ្តើម......................................................................................................................................៣

២-របកកំហើញ.....................................................................................................................................៥

២.១-ទិន្នន័យស្តីពីសេវាកម្មជំនួយផ្នែកច្បាប់ដែលមាន..................................................................................៥

២.១.១-ចំនួនមេធាវីជំនួយផ្នែកច្បាប់ និងការទៅចុះដល់ទីតាំងភូមិសាស្ត្រ..........................................................៥

២.១.២-ចំនួនរឿងក្តីសំរាប់អ្នកផ្តល់ជំនួយផ្នែកច្បាប់នីមួយៗ............................................................................១០

២.១.៣-ប្រភេទរឿងក្តីជំនាញ និងឯកទេសកម្មនៃអ្នកផ្តល់ជំនួយផ្នែកច្បាប់......................................................១២

២.២-ទស្សនៈស្តីពីបញ្ហាប្រឈម និងទស្សនៈចំពោះជំនួយផ្នែកច្បាប់ក្នុងប្រទេសកម្ពុជាសំរាប់ពេលអនាគត............១៣

៣-សេចក្តីសន្និដ្ឋាន................................................................................................................................១៧

៤-ឧបសម្ព័ន្ធ- កំរងព័ត៌មានសង្ខេបស្តីពីអ្នកផ្តល់ជំនួយផ្នែកច្បាប់.....................................................................១៩

# អក្សរកាត់នៃក្រុមអ្នកផ្តល់ជំនួយផ្នែកច្បាប់

| | |
|---|---|
| ADHOC | សមាគមអាដហុកការពារសិទ្ធិមនុស្ស និង អភិវឌ្ឍន៍នៅកម្ពុជា |
| BACK | គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា |
| ASF | សមាគមមេធាវីឥតព្រំដែន នៃប្រទេសបារាំង |
| CDP | ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា |
| CHRAC | គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា |
| CLEC | មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ |
| CWCC | អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ |
| IBJ | អង្គការស្ពានយុត្តិធម៌អន្តរជាតិ |
| LAC | អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា |
| LAD | នាយកដ្ឋានការពារជនក្រីក្រ នៃ គណៈមេធាវី |
| LICADHO | អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ |
| LSCW | អង្គការជំនួយផ្លូវច្បាប់ដល់កុមារ និង ស្ត្រី |
| PJJ | អង្គការការពារយុត្តិធម៌កុមារ |

# ១.សេចក្តីផ្តើម

របបខ្មែរក្រហម និងសង្គ្រាមស៊ីវិលអស់រយៈពេលជាច្រើនឆ្នាំ បានបំផ្លិចបំផ្លាញប្រព័ន្ធតុលាការកម្ពុជាយ៉ាងធ្ងន់ធ្ងរ។ ដោយការមកដល់របស់អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិសំរាប់ប្រទេសកម្ពុជា (UNTAC) នៅដើមទសវត្សន៍ឆ្នាំ១៩៩០ ប្រទេសកម្ពុជាបានស្ថាបនាឡើងវិញនូវប្រព័ន្ធតុលាការឯករាជ្យមួយក្រោមជំនួយពីអន្តរជាតិ។ ចាប់តាំងពីពេលនោះមក គោលបំណងសំខាន់ គឺដើម្បីបណ្តុះឱ្យមាននីតិរដ្ឋនៅក្នុងប្រទេសកម្ពុជា។ ជាលទ្ធផល ការរៀបចំដ៏ស្មុគស្មាញថ្មីមួយនៃច្បាប់និងស្ថាប័ននានា ត្រូវបានបង្កើតឡើង។ កំណែទម្រង់ថ្មីៗជាច្រើនទាំងនេះ គឺពិបាកស្វែងយល់ ហើយស្ថាប័នថ្មីៗជាច្រើននៅតែមិនអាចឱ្យប្រជាពលរដ្ឋកម្ពុជាទូទៅ ទទួលបានព័ត៌មានទូលំទូលាយនៅឡើយ។ ដូចនេះ វាជាការចាំបាច់ណាស់ដែលត្រូវតែមានមេធាវីការពារកូនក្តីដែលជាជនរងគ្រោះ នៃការរំលោភបំពានសិទ្ធិមនុស្សនិងជនជាប់ចោទចោទនានា នៅក្នុងបរិបទនៃប្រព័ន្ធតុលាការ និងច្បាប់ថ្មីៗទាំងនោះ។ ដោយសារតែប្រទេសកម្ពុជា គឺជាប្រទេសកំពុងអភិវឌ្ឍន៍ ដែលមានចំណូលទាបមានកូនក្តីជាច្រើនដែលមិនមានលទ្ធភាពបង់ប្រាក់សំរាប់ការផ្តល់យោបល់ផ្នែកច្បាប់បានទេ ហើយផ្ទុយទៅវិញ គេត្រូវពឹងផ្អែកទៅលើសេវាកម្មជំនួយផ្នែកច្បាប់ដែលមិនគិតកំរៃ។ ម្យ៉ាងទៀត កង្វះធនធាន និងសមត្ថភាពរបស់រដ្ឋទន់ខ្សោយ មានតែសេវាកម្មជំនួយផ្នែកច្បាប់តិចតួចកំពុងតែមាននាពេលបច្ចុប្បន្ន តាមរយៈអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ភាគច្រើនកំពុងធ្វើប្រតិបត្តិការក្រៅវិសាលភាព នៃការផ្តល់ថវិកាដោយរាជរដ្ឋាភិបាល ដើម្បីបំពេញតំរូវការបន្ទាន់បំផុតសំរាប់ការងារជំនួយផ្នែកច្បាប់នេះ។

សិទ្ធិសំខាន់សំរាប់ការទទួលបាននូវការពារតាមផ្លូវច្បាប់ប្រកបដោយប្រសិទ្ធភាព គឺមានចែងក្នុងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។ លើសពីនេះទៀត មាត្រា ៣០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា ជនជាប់ចោទ នឹងចូលបង្ហាញខ្លួនក្នុងពេលសវនាការរបស់តុលាការដោយផ្ទាល់ និងត្រូវអមដោយមេធាវីម្នាក់ដែលខ្លួនជ្រើសរើស ឬ តាមសំណើចាត់តាំងមេធាវីឱ្យខ្លួន។ បន្ថែមពីនេះ មាត្រា ៣០១ ចែងថា ជំនួយពីមេធាវីត្រូវតែមានដាច់ខាត កាលណាការជំនុំជម្រះក្នុងព្រហ្មទណ្ឌ ឬកាលណាជនជាប់ចោទជាអនីតិជន។ ក្នុងកាលៈទេសៈនេះ បើជនជាប់ចោទមិនបានជ្រើសរើសមេធាវីទេ មេធាវីនឹងត្រូវបានចាត់តាំងដោយគំនិតផ្តួចផ្តើមរបស់ប្រធានតុលាការ។ បទប្បញ្ញត្តិទាំងនេះ មានចែងយ៉ាងច្បាស់ពីលក្ខខណ្ឌច្បាប់តំរូវសំរាប់ប្បញ្ញត្តិនៃសេវាកម្មជំនួយផ្នែកច្បាប់។

គិតមកត្រឹមឆ្នាំ២០១០ ព័ត៌មានជាក់លាក់មានតិចតួចស្តីអំពីសមត្ថភាពដែលមានក្នុងសេវាកម្មជំនួយផ្នែកច្បាប់នៅក្នុងប្រទេសកម្ពុជា និងក្នុងការបំពេញកិច្ចជារួម។ ការសិក្សាថ្មីៗ ជាច្រើនក្នុងការធ្វើផែនទីស្តីពីតំរូវការចាំបាច់, សមត្ថភាព, និងការអនុវត្តជំនួយផ្នែកច្បាប់ក្នុងប្រទេសកម្ពុជា គឺត្រូវបានបោះពុម្ពផ្សាយក្នុងឆ្នាំ២០០៦ ដោយក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធមិ ដោយមានជំនួយឧបត្ថម្ភពីទីភ្នាក់ងារអភិវឌ្ឍន៏អន្តរជាតិរបស់សហរដ្ឋអាមេរិក (USAID)។ ការស្ទង់មតិនោះបានរកឃើញថា បច្ចុប្បន្ននៅប្រទេសកម្ពុជា នៅមិនមានក្របខណ្ឌច្បាប់, ស្ថាប័ន និងគោលនយោបាយទូលំទូលាយ

នៅថ្នាក់ជាតិសំរាប់ណែនាំជាបទប្បញ្ញត្តិ និងបទញ្ញាសំរាប់ការផ្តល់សេវាកម្មជំនួយផ្នែកច្បាប់ទេ។[1] តាំងពីនោះមក ទើបរាជរដ្ឋាភិបាលកម្ពុជា និងម្ចាស់ជំនួយអន្តរជាតិ មកជួបប្រជុំពិភាក្សាក្នុងក្របខណ្ឌ នៃសកម្មភាព កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយផ្តោតសំខាន់លើការរៀបចំ និងការបង្កើតគោលនយោបាយជំនួយផ្នែកច្បាប់សំរាប់ប្រទេសកម្ពុជា។

របាយការណ៍នេះ មានគោលបំណងដើម្បីផ្តល់ព័ត៌មានពាក់ព័ន្ធនឹងកិច្ចពិភាក្សាទាំងនេះអំពីក្របខណ្ឌជំនួយផ្នែកច្បាប់ដែលបានដាក់បញ្ចូល និងរាប់បញ្ចូលតាមរយៈគោលដៅសំខាន់ដូចជាៈ (១) បច្ចុប្បន្នកម្មអំពីចំនួនមេធាវីជំនួយផ្នែកច្បាប់ដែលមានស្រាប់ (ធ្វើការពេញម៉ោង) ក្នុងប្រទេសកម្ពុជា ដោយសារតែវាត្រូវបានគេសន្មត់ថា មានការផ្លាស់ប្តូរខ្លះៗនូវលទ្ធផលនៃរបាយការណ៍ស្ទង់មតិឆ្នាំ២០០៦, (២) កំណត់វត្តមានមេធាវីជំនួយផ្នែកច្បាប់នៅក្រៅទីប្រជុំជននៃខេត្តនីមួយៗ និងគម្លាតនៃទំនាក់ទំនងនៅក្នុងតំបន់សំរាប់ការផ្តល់សេវាកម្មផ្នែកច្បាប់, (៣) ផ្តល់ការបង្ហាញអំពីសមត្ថភាពរបស់អ្នកផ្តល់ជំនួយផ្នែកច្បាប់ (ពោល គឺរឿងក្តីដែលពួកគេកំពុងចាត់ការ) និង (៤) កំណត់ឯកទេសកម្មប្រភេទករណីរបស់អ្នកផ្តល់ជំនួយផ្នែកច្បាប់ដែលកំពុងមានស្រាប់ (ពោល គឺថា តើពួកគេផ្តោតលើជំនួយផ្នែកច្បាប់ជាលក្ខណៈទូទៅ ឬលើក្រុមគោលដៅជាក់លាក់)។ លើសពីនេះក៏មានសំនួរខ្លះ ត្រូវបានចោទសួរនៅចុងបញ្ចប់នៃកិច្ចសម្ភាសន៏នីមួយៗអំពីគំនិតរបស់អ្នកឆ្លើយ អំពីតំរូវការចាំបាច់ដែលត្រូវធ្វើដើម្បីធ្វើឱ្យស្ថានភាពនៃសេវាកម្មជំនួយផ្នែកច្បាប់ក្នុងប្រទេសកម្ពុជាមានភាពប្រសើរឡើង។ កំរងព័ត៌មានដែលភ្ជាប់មួយជានៅក្នុងឧបសម្ព័ន្ធ ក៏សង្ខេបនូវចំណុចសំខាន់ៗនៃអ្នកផ្តល់ជំនួយផ្នែកច្បាប់ ដែលបានផ្តល់កិច្ចសម្ភាសន៏នីមួយៗផងដែរ។

ការសិក្សានេះ ត្រូវបានផ្តួចផ្តើមឡើងដោយលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ-សមាគម-ការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) ដែល គឺជាសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលចំនួន ២៣ កំពុងធ្វើការក្នុងវិស័យសិទ្ធិមនុស្ស នីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យ នៅក្នុងប្រទេសកម្ពុជា។ នៅក្នុងចំណោមសមាជិករបស់ខ្លួនមានសមាជិកមួយចំនួនរបស់ CHRAC មានភាពសកម្មក្នុងការផ្តល់សេវាកម្មជំនួយផ្នែកច្បាប់ ក្នុងនោះមាន អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP), អង្គការជួយផ្នែកច្បាប់នៃកម្ពុជា (LAC), អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC), អង្គការការពារយុត្តិធម៌កុមារ (PJJ), និងសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៏នៅកម្ពុជា (ADHOC)។

ការស្ទង់មតិលំអិតត្រូវបានធ្វើឡើងដោយលេខាធិការដ្ឋាន CHRAC ក្នុងកំឡុងពេលចាប់ពីខែសីហា ដល់ខែតុលា ឆ្នាំ២០១០។ គំរោងស្ទង់មតិនេះ មានកំរិតនៅក្នុងការពិនិត្យមើលអំពីវិសាលភាពនិងភាពស៊ីជំរៅស្តីពីការផ្តល់ជំនួយផ្នែកច្បាប់ ដោយសារតែ គ្មានធនធានបន្ថែមសំរាប់គោលបំណងនេះឡើយ។ ជាសរុប គឺថាមានកិច្ចសម្ភាសន៏ចំនួន១២ ត្រូវបានធ្វើឡើងដោយមានការចូលរួមពីអ្នកតំណាងសំខាន់ៗនៅក្នុងចំណោមអ្នកផ្តល់ជំនួយផ្នែកច្បាប់ រួមបញ្ចូលទាំងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (BACK) ផងដែរ។ របាយការណ៍ខាងក្រោមនឹងបង្ហាញពីរបកគំហើញទាំងអស់។ លទ្ធផលទាំងអស់ត្រូវបានធ្វើឡើងដោយផ្អែកលើព័ត៌មានដែលបានផ្តល់ដោយអង្គការនីមួយៗផ្ទាល់ក្នុងកំឡុងពេលសម្ភាសន៏។ ដូច្នេះ

---

[1] ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ៈ "ជំនួយផ្នែកច្បាប់ក្នុងប្រទេសកម្ពុជា, ការអនុវត្ត, ការយល់ដឹង និង តំរូវការ" ការសិក្សាបានផ្អែកលើការស្ទង់មតិថ្នាក់ជាតិនៅភ្នំពេញ ក្នុងខែធ្នូ ឆ្នាំ២០០៦, ទំព័រទី ១០, [ដែលចាប់ពីពេលនេះតទៅ ហៅថា *របាយការណ៏ស្ទង់មតិជំនួយផ្នែកច្បាប់ ឆ្នាំ២០០៦*]

CHRAC មិនអាចធានាអំពីភាពត្រឹមត្រូវជាក់លាក់ទាំងស្រុង ទៅលើព័ត៌មានដែលដាក់ក្នុងរបាយការណ៍នេះទេ ពីព្រោះថាទាំងនោះ គឺបានមកពីចងក្រងនូវទស្សនៈយោបល់ និងព័ត៌មានផ្ទាល់ដកស្រង់ពីអ្នកសំភាសន៍ម្នាក់ៗប៉ុណ្ណោះ។

## ២. របកគំហើញ

កិច្ចសម្ភាសន៍ ត្រូវបានបង្កើតឡើងដោយសំនួរនាំមុខចំនួន១០ (សូមមើលសំនួរនាំមុខក្នុងឧបសម្ព័ន្ធ)។ សំនួរភាគច្រើនមានគោលបំណង ដើម្បីប្រមូលទិន្នន័យអំពីសមត្ថភាពរបស់អ្នកផ្តល់ជំនួយផ្នែកច្បាប់។ម្យ៉ាងទៀត សំនួរចុងក្រោយបានផ្តល់ឱកាសដល់អ្នកឆ្លើយសំនួរបង្ហាញនូវទស្សនៈទូទៅរបស់គេ ស្តីពីបញ្ហាប្រឈមបច្ចុប្បន្ន និងវិធានការដែលចាំបាច់ត្រូវធ្វើដើម្បីធ្វើឱ្យសេវាកម្មជំនួយផ្នែកច្បាប់មានភាពល្អប្រសើរឡើងនៅពេលអនាគត។ ហេតុដូច្នេះ ការវិភាគទៅលើបទសម្ភាសន៍ទាំងនេះ គឺត្រូវបានបែងចែកជាពីរផ្នែកៈ ផ្នែកទីមួយ គឺការពិនិត្យមើលអំពីទិន្នន័យដែលពាក់ព័ន្ធនឹងសេវាកម្មផ្នែកច្បាប់ ដែលកំពុងមាន ហើយផ្នែកទីពីរ គឺការផ្តល់ទិដ្ឋភាពរួមអំពីទស្សនៈផ្សេងៗដែលបានលើកឡើងទាក់ទងនឹងការធ្វើឱ្យជំនួយផ្នែកច្បាប់មានលក្ខណៈល្អប្រសើរឡើង នៅពេលអនាគតសំរាប់ប្រទេសកម្ពុជា។

### ២.១_ទិន្នន័យស្តីពីសេវាកម្មជំនួយផ្នែកច្បាប់ដែលមាន

កំរិតនៃការប្រមូលទិន្នន័យជាប្រព័ន្ធ និងការចងក្រងនៃព័ត៌មានពាក់ព័ន្ធក្នុងសំណុំរឿងមានលក្ខណៈប្រែប្រួលយ៉ាងច្រើននៅក្នុងចំណោមអង្គការជំនួយផ្នែកច្បាប់នីមួយៗ។ អង្គការខ្លះមានប្រព័ន្ធគ្រប់គ្រងសំណុំរឿងកណ្តាលមួយ ឯអង្គការខ្លះទៀតមិនមាន ដែលនាំឱ្យពិបាកក្នុងការបង្កើតឱ្យមានទិន្នន័យជាក់លាក់សំរាប់រយៈពេលធ្វើការសំភាសន៍ដ៏ខ្លីបែបនេះ។ ហេតុដូច្នេះ ការសិក្សានេះបានកំណត់ជាមុននូវវិសាលភាពនៃទិន្នន័យដែលប្រមូលបាន ដើម្បីអាចឱ្យមានទំរង់ប្រៀបធៀបខ្លះនៅក្នុងចំណោមអ្នកផ្តល់ជំនួយផ្នែកច្បាប់។ បញ្ហាប្រឈមទាំងនេះ ចាំបាច់ត្រូវយកពិចារណានៅពេលដែលធ្វើការអាននូវរបកគំហើញនៅក្នុងរបាយការណ៍នេះ។

### ២.១.១-ចំនួនមេធាវីជំនួយផ្នែកច្បាប់ និងការចុះទៅដល់ទីតាំងភូមិសាស្ត្រ

គិតមកដល់ឆ្នាំ២០១០ នៅក្នុងប្រទេសកម្ពុជា មានអ្នកផ្តល់ជំនួយផ្នែកច្បាប់សំខាន់ៗទៅដល់ប្រជាពលរដ្ឋក្រីក្រភាគច្រើន ជាអង្គការមិនមែនរដ្ឋាភិបាល ហើយលើកលែងតែតួអង្គមួយប៉ុណ្ណោះ ដែលមិនមែនជាអង្គការមិនមែនរដ្ឋាភិបាល គឺគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ ដោយហេតុនេះ ការស្ទង់មតិនេះបានយល់ស្របភាគច្រើន ទៅលើរបកគំហើញនៃរបាយការណ៍ស្ទង់មតិស្តីពីជំនួយផ្នែកច្បាប់ ឆ្នាំ២០០៦។ ទោះបីជាយ៉ាងណាក៏ដោយ មានការការផ្លាស់ប្តូរសំខាន់មួយ ដែលបានកើតឡើងក្នុងកំឡុងពេល៤ឆ្នាំកន្លងទៅនេះ គឺៈ សមត្ថភាពរបស់គណៈមេធាវីបានកើនឡើងច្រើនក្នុងកំរិតមួយ ដែលអាចធ្វើឱ្យប៉ះពាល់ខ្លះៗដល់តុល្យភាពសេវាកម្មជំនួយផ្នែកច្បាប់ ដែលផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាល។

ការស្ទង់មតិ ស្តីពីជំនួយផ្នែកច្បាប់ឆ្នាំ២០០៦ បានផ្តល់នូវទិដ្ឋភាពរួមអំពីចំនួន និងទីតាំងរបស់មេធាវីជំនួយផ្នែកច្បាប់។[2] ការសិក្សានេះផ្តល់នូវបច្ចុប្បន្នភាពនៃទិដ្ឋភាពរួមនេះ ដោយបានបង្ហាញអំពីចំនួនមេធាវី ដែលកំពុងប្រកបវិជ្ជាជីវៈផ្តល់ជំនួយផ្នែកច្បាប់នៅក្នុងរាជធានីភ្នំពេញ និងនៅតាមបណ្តាខេត្តនានា (សូមមើលតារាងទី១)។ នៅក្នុងករណីភាគច្រើនវត្តមានរបស់មេធាវីក្នុងខេត្តមួយអាចស្មើនឹងចំនួនការិយាល័យខេត្តដែលមានរបស់អង្គការមិនមែនរដ្ឋាភិបាលនីមួយៗ។ គួរកត់សំគាល់ថា មេធាវីផ្តល់ជំនួយផ្នែកច្បាប់ក្នុងខេត្តមួយអាចមានឱកាសផ្តល់សេវាកម្មជំនួយផ្នែកច្បាប់ដល់កូនក្តីនៅក្នុងខេត្ត ដែលស្ថិតនៅជិតៗគ្នា។ លើសពីនេះទៀតមានអង្គការមិនមែនរដ្ឋាភិបាលខ្លះក៏បានបិទការិយាល័យខេត្តរបស់ខ្លួន ហើយ ផ្តោតលើការផ្តល់សេវាកម្មទៅតំបន់ផ្សេងៗ ដោយបង្កើនចំនួនមេធាវីធ្វើការពីស្នាក់ការកណ្តាលរបស់ខ្លួនក្នុងទីក្រុងភ្នំពេញវិញ។ ទោះបីជាយ៉ាងណាក៏ដោយ "សេវាកម្មជំនួយផ្នែកច្បាប់ចល័ត" ទាំងនេះ និងការចុះដល់ទីតាំងភូមិសាស្ត្រផ្សេងៗរបស់គេ មិនអាចយកមកធ្វើការវាយតម្លៃនៅក្នុងរបាយការណ៍នេះទេ ដោយសារតែ ជាញឹកញាប់ អង្គការមិនមែនរដ្ឋាភិបាលទាំងនេះមិនមានព័ត៌មានជាក់ពីសំរាប់យកមកប្រើប្រាស់បាន។ ហើយជាចុងក្រោយ វិធីសាស្ត្រថ្មីៗសំរាប់ជំនួយផ្នែកច្បាប់ ដូចជា តាមរយៈក្រុមអ្នកច្បាប់ឯកជនសំរាប់ការពារប្រយោជន៍សាធារណៈ ដូចជា ក្រុមមេធាវីសំរឹទ្ធ (Samreth Law Group) ជាដើម មិនត្រូវបានយកមកពិចារណាសំរាប់គោលបំណងវិភាគនៃរបាយការណ៍នេះទេ។

ការផ្លាស់ប្តូរសំខាន់មួយ បើធ្វើការប្រៀបធៀបជាមួយស្ថានភាពនៃសេវាកម្មជំនួយផ្នែកច្បាប់ក្នុងឆ្នាំ២០០៦ គឺការបន្ថែមក្របខណ្ឌជំនួយផ្នែកច្បាប់ថ្មីមួយនៅតាមបណ្តាខេត្តដែលបានផ្តល់មូលនិធិដោយប្រទេសបារាំង តាមរយៈការគ្រប់គ្រងផ្ទាល់ដោយសមាគមមេធាវីឥតព្រំដែននៃប្រទេសបារាំង (Avocats Sans Frontières-ASF) ដោយសហប្រតិបត្តិការជាមួយគណៈមេធាវី និងការពង្រីកសមត្ថភាពរបស់នាយកដ្ឋានការពារជនក្រីក្ររបស់គណៈមេធាវី។

ក្នុងភាពជាដៃគូជាមួយគណៈមេធាវី សមាគមមេធាវីឥតព្រំដែននៃប្រទេសបារាំង (ASF) គាំទ្រការបង្កើតក្របខណ្ឌជំនួយផ្នែកច្បាប់មួយសំរាប់ជួយដល់ប្រជាពលរដ្ឋដែលងាយរងគ្រោះបំផុត នៅតាមសាលាដំបូងនៃបណ្តាខេត្តនានានៅទូទាំងប្រទេស។ កម្មវិធីលើកទីមួយ ត្រូវបានបង្កើតឡើងរវាងពីឆ្នាំ២០០៦ និងឆ្នាំ២០០៨ ក្រោមជំនួយរបស់សហភាពអឺរ៉ុប (European Union)។ កម្មវិធីលើកទីពីរ ដែលត្រូវបានគាំទ្រដោយទីភ្នាក់ងារអភិវឌ្ឍន៍ប្រទេសបារាំង (Agence Française de Développement) បានចាប់ផ្តើមឡើងវិញនៅខែមីនា ឆ្នាំ២០១០ ដើម្បីពង្រឹងបន្ថែមទៅលើក្របខណ្ឌសេវាកម្មមេធាវីនេះ។ គោលបំណងចំបងនៃកម្មវិធីនេះ គឺដើម្បីជួយបង្កើនវត្តមានមេធាវីខ្មែរ នៅតាមបណ្តាខេត្តទាំងអស់ ដែលមានអត្ថិភាពតុលាការ។ ចំនួនមេធាវីសរុបទាំងអស់មាន ២២នាក់ (រួមបញ្ចូលទាំង មេធាវី២នាក់ ក្នុងខេត្តបាត់ដំបង និង ២នាក់ទៀតក្នុងខេត្តសៀមរាប) ត្រូវបានជ្រើសរើសដោយគណៈមេធាវី និងសមាគមមេធាវីឥតព្រំដែននៃប្រទេសបារាំង ដើម្បីចូលរួមជាផ្នែកមួយនៃកម្មវិធីនេះ។ មេធាវីទាំងនេះធ្វើការងារដោយទទួលនូវប្រាក់បំណាច់ប្រចាំខែចំនួនប្រហែល ៤០០ ដុល្លារសហរដ្ឋអាមេរិក ដែលធ្វើតាមកិច្ចសន្យាសំរាប់ការពាររឿងក្តីយ៉ាងហោចណាស់ ៣រឿង (ប្រសិនបើជារឿងក្តីព្រហ្មទណ្ឌធំៗ) ឬ យ៉ាងហោចណាស់ ១០ រឿងក្តី (ប្រសិនបើជារឿងក្តីរដ្ឋប្បវេណី ឬ រឿងក្តីព្រហ្មទណ្ឌមធ្យម) ក្នុង១ខែៗ។ សំរាប់ពេលដែលនៅសល់ មេធាវីទាំងនេះអាចការពាររឿងក្តីឯកជនបាន។ គោលការណ៍នៃប្រព័ន្ធនេះ គឺដើម្បីគាំទ្រទំរង់គំរូការងាររួមគ្នា គឺថា ការពាររឿងក្តីជំនួយផ្នែកច្បាប់ និងរឿងក្តីឯកជនរួមគ្នា ដើម្បីលើកទឹកចិត្តឱ្យមេធាវីធ្វើការនៅតាមខេត្តនានា តាមរយៈ

[2] សូមមើល *របាយការណ៍ស្ទង់មតិជំនួយផ្នែកច្បាប់ ឆ្នាំ២០០៦*, ទំព័រទី១៤

ការបង្កើតសកម្មភាព ដែលមានលក្ខណៈយូរអង្វែង។ នោះមានន័យថា មេធាវីទាំងនេះមិនមែនជាមេធាវីធ្វើការពេញម៉ោងសំរាប់សេវាកម្មជំនួយផ្នែកច្បាប់ទេ ហើយដូចនេះ គេអាចសន្មត់បានថាចំនួនរឿងក្ដីរបស់ពួកគេ ជាទូទៅទាបជាងចំនួនរឿងក្ដីរបស់មេធាវីជំនួយផ្នែកច្បាប់ដែលធ្វើការងារពេញម៉ោង។ ដូចនេះ យើងគួរតែបែងចែកភាពខុសគ្នាដោយប្រុងប្រយ័ត្នអំពីចំនួនសរុបនៃមេធាវីជំនួយផ្នែកច្បាប់ដែលមាន ដូចដែលបានបង្ហាញក្នុងតារាងពាក់ព័ន្ធនឹងចំនួនមេធាវីធ្វើការពេញម៉ោង ឬមេធាវីមិនពេញម៉ោងសំរាប់សេវាកម្មជំនួយផ្នែកច្បាប់។ បើមិនដូច្នោះទេ តារាងនោះអាចផ្ដល់នូវការវិភាគខុសអំពីសមត្ថភាព (ឬលទ្ធភាពដែលមាន) របស់មេធាវីពិតប្រាកដដែលមាន។

**តារាងទី១ ចំនួន និងទីតាំងនៃមេធាវីជំនួយផ្នែកច្បាប់ (ត្រឹមខែសីហា និង ខែកញ្ញា ឆ្នាំ២០១០)**

| អង្គការ/ ខេត្ត | ADHOC | ASF/BAKC ** | BAKC/LAD* | CDP | CLEC | CWCC | IBJ | LAC | LICADHO | LSCW | PJJ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|
| បន្ទាយមានជ័យ | | 1 | | | | 1 | | 1 | | | | 3 |
| បាត់ដំបង | | 2 | | 1 | | | | 2 | | | | 5 |
| កំពង់ចាម | | 1 | | | | | | 1 | | | | 2 |
| កំពង់ឆ្នាំង | | 1 | | | | | | | | | | 1 |
| កំពង់ស្ពឺ | | 1 | | | | | | | | | | 1 |
| កំពង់ធំ | | 1 | | | | | | | | | | 1 |
| កំពត | | 1 | | | | | | | | | | 1 |
| កណ្ដាល | | 1 | | | | | | 4 | | | | 5 |
| កោះកុង | | 1 | | | | | | | | 1 | | 2 |
| ក្រចេះ | | 1 | | | | | | | | | | 1 |
| មណ្ឌលគិរី | | 1 | | | | | | | | | | 1 |
| ភ្នំពេញ | 2 | - | 15 | 19 | 6 | 2 | 3 | 17 | 5 | 5 | 4 | 78 |
| ព្រះវិហារ | | 1 | | | | | | | | | | 1 |
| ព្រៃវែង | | 1 | | | | | 1 | | | | | 2 |
| ពោធិសាត់ | | 1 | | | | | 1 | | | | | 2 |
| រតនៈគិរី | | 1 | | | | | | 1 | | | | 2 |
| សៀមរាប | | 2 | | 2 | | 1 | | 1 | | | | 6 |
| ព្រះសីហនុ | | 1 | | | | | | | | | | 1 |
| ស្ទឹងត្រែង | | 1 | | | | | | | | | | 1 |
| ស្វាយរៀង | | 1 | | | | | | | | | | 1 |
| តាកែវ | | 1 | | | | | 1 | | | | | 2 |
| **សរុប** | 2 | 22 | 15 | 22 | 6 | 4 | 6 | 27 | 5 | 6 | 4 | **119** |

*កំណត់សំគាល់:*

** យោងទៅតាមព័ត៌មានផ្ដល់ដោយគណៈមេធាវី គឺថា មានតែមេធាវីចំនួន៨នាក់ប៉ុណ្ណោះនៅក្នុងចំណោមមេធាវីរបស់នាយកដ្ឋានការពារជនក្រីក្រសរុបចំនួន ១៥ នាក់ ដែលធ្វើការពេញម៉ោងសំរាប់រឿងក្ដីជំនួយផ្នែកច្បាប់ ។*

*** គំរោងគាំទ្ររបស់ ASF ផ្ដល់នូវមេធាវីធ្វើការមិនពេញម៉ោងចំនួនម្នាក់នៅតាមខេត្តដែលមានសាលាដំបូងនីមួយៗ លើកលែងតែនៅខេត្តបាត់ដំបង និងខេត្តសៀមរាប ដែលមានមេធាវីចំនួន២ នាក់ ។*

ក្រៅពីភាពជាដៃគូជាមួយនឹងសមាគមមេធាវីឥតព្រំដែននៃប្រទេសបារាំង គណៈមេធាវីក៏អាចបង្កើនសមត្ថភាពរបស់នាយកដ្ឋានការពារជនក្រីក្ររបស់ខ្លួនបានផងដែរ ។ នាយកដ្ឋានការពារជនក្រីក្រ ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៨ បានត្រូវចាប់ផ្ដើមសកម្មភាពឡើងវិញ នៅពេលដែលនាយកដ្ឋាននេះ បង្កើនចំនួនមេធាវីជាលើកដំបូងពី ៩នាក់ នៅឆ្នាំ២០០៨ រហូតដល់១៥នាក់ នៅឆ្នាំ២០១០ ។ នាយកដ្ឋានការពារជនក្រីក្រ ត្រូវបានផ្ដល់មូលនិធិតាមរយៈវិភាគទានប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាលកម្ពុជា នូវទឹកប្រាក់ចំនួន ១០០លានរៀល និង មូលនិធិពីខាងក្រៅបន្ថែមពីសហរដ្ឋអាមេរិក តាមរយៈវិទ្យាស្ថានគ្រប់គ្រងបូព៌ា-បស្ចិម (EWMI) ។ ក្រោយមកក៏មានឱកាសសំរាប់បូកបញ្ចូលមេធាវី ដែលទើបបញ្ចប់ការសិក្សាថ្មីចំនួន៦នាក់ចូលរួមក្នុងការងារជំនួយផ្នែកច្បាប់ជារៀងរាល់ឆ្នាំផងដែរ ។ គណៈមេធាវី បានផ្ដល់ព័ត៌មានថា មានតែពាក់កណ្ដាលនៃចំនួនមេធាវីធ្វើការនៅក្នុងនាយកដ្ឋានការពារជនក្រីក្រ ជាមេធាវីធ្វើការពេញម៉ោងទៅលើរឿងក្ដី ។ រាជរដ្ឋាភិបាលកម្ពុជា បានផ្ដល់វិភាគទានបន្ថែមចំនួន ១០០លានរៀលដែរក្នុងមួយឆ្នាំទៅដល់ក្រសួងកិច្ចការនារី ដែលធ្លាប់ផ្ដល់សេវាកម្មជំនួយផ្នែកច្បាប់ក្នុងការងាររបស់ខ្លួន ។ ដូចនេះ បើបូកបញ្ចូលវិភាគទានទាំងពីរនេះរួមគ្នា រាជរដ្ឋាភិបាលកម្ពុជាបានផ្ដល់វិភាគទានចំនួន ២០០ លានរៀល ក្នុងមួយឆ្នាំ សំរាប់សេវាកម្មជំនួយផ្នែកច្បាប់ ( តិចជាង ៥០,០០០ ដុល្លារសហរដ្ឋអាមេរិក) ។

នៅពេលប្រៀបធៀបតារាងដែលបានធ្វើបច្ចុប្បន្នភាពក្នុងឆ្នាំ២០១០ជាមួយនឹងព័ត៌មានដែលបានផ្ដល់ក្នុងការស្ទង់មតិឆ្នាំ២០០៦ មានចំណុចមួយចំនួន អាចបញ្ជាក់ពីភាពដូចគ្នា និងភាពខុសគ្នា ដូចខាងក្រោម:

(១) អង្គការមិនមែនរដ្ឋាភិបាល នៅតែជាតួអង្គផ្ដល់សេវាកម្មជំនួយផ្នែកច្បាប់ក្នុងប្រទេសកម្ពុជាច្រើនជាងគេ ។

(២) ចំនួនសរុបនៃមេធាវីជំនួយផ្នែកច្បាប់ដែលមាន បានកើនឡើង (ទោះបីជាយ៉ាងណាក៏ដោយ ចំនួននេះអាចសមាមាត្រនឹងប្រជាពលរដ្ឋកម្ពុជា ដែលបានកើនឡើងផងដែរ ចន្លោះពីឆ្នាំ ២០០៦ និង ឆ្នាំ២០១០ ប្រហែល ចាប់ពី ១៣ លាននាក់ ដល់ជាង ១៤ លាននាក់) ។

(៣) ការប្រែប្រួលសំខាន់ទាក់ទងនឹងសមត្ថភាពសេវាកម្មជំនួនផ្នែកច្បាប់កើនឡើង ដោយសារមានការចូលរួមពីគណៈមេធាវី ជាពិសេសតាមរយៈគំរោងបន្ថែមមេធាវីនៅតាមបណ្ដាខេត្ត ដែលគ្រប់គ្រងដោយសមាគមមេធាវីឥតព្រំដែននៃប្រទេសបារាំង និងការពង្រីកសមត្ថភាពមេធាវីរបស់នាយកដ្ឋានការពារជនក្រីក្រ ។

(៤) ភាគច្រើននៃចំនួនកើនឡើងបានត្រូវសំរេចឡើង តាមរយៈការបន្ថែមនៃមេធាវីជំនួយផ្នែកច្បាប់ដែលធ្វើការមិនពេញម៉ោង ។ ចំនួននៃមេធាវីជំនួយផ្នែកច្បាប់ដែលធ្វើការពេញម៉ោងនៅតែដដែល (តិចឬច្រើន) បើប្រៀបធៀបទៅនឹងឆ្នាំ២០០៦ ។

(៥) សមត្ថភាពរបស់អង្គការមិនមែនរដ្ឋាភិបាលនៅតែជាចំនួនដដែល បើប្រៀបធៀបទៅនឹងឆ្នាំ២០០៦។ អង្គការ CDP និងអង្គការ LAC នៅតែជាអង្គការដែលមានសមត្ថភាពសំរាប់ផ្តល់សេវាកម្ម ជំនួយផ្នែកច្បាប់ ទោះបីជាអង្គការទាំងពីរផ្ទេរតួនាទីគ្នា គឺថាឥឡូវនេះ អង្គការ LAC ជាអ្នកផ្តល់ជំនួយផ្នែកច្បាប់ធំបំផុតក្នុងប្រទេស កម្ពុជា។

(៦) សមត្ថភាពនៃអង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់ជំនួយផ្នែកច្បាប់ខ្នាតមធ្យម ហាក់នៅមានកំរិតដដែល។ ដោយឡែក តួអង្គថ្មីមួយបានលេចរូបរាងឡើង គឺអង្គការស្ពានយុត្តិធម៌អន្តរជាតិ (IBJ)។

(៧) ពាក់ព័ន្ធនឹងតំបន់ទីតាំងភូមិសាស្ត្រ គម្រោងរបស់ក្រុមមេធាវីឥតព្រំដែននៃប្រទេសបារាំង អាចគ្របដណ្តប់ខេត្ត ដែលកាលពីមុនមិនមានមេធាវីជំនួយផ្នែកច្បាប់នៅជាអចិន្ត្រៃយ៍។ ទោះបីជាយ៉ាងណាក៏ដោយ នៅទន្ទឹមគ្នានេះ ចំនួនមេធាវីជំនួយផ្នែកច្បាប់ដែលធ្វើការពេញម៉ោងនៅក្នុងខេត្តនានា ដែលភាគច្រើនជាបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ជាទូទៅ បានថយចុះ គឺថាៈ នៅក្នុងឆ្នាំ២០០៦ មេធាវីជំនួយផ្នែកច្បាប់ធ្វើការពេញម៉ោងចំនួន ៣៧នាក់ ក្នុងចំណោម៨៩នាក់នៅធ្វើការអចិន្ត្រៃយ៍នៅតាមបណ្តាខេត្តនានា (ស្មើនឹង ៤២ ភាគរយ) ចំណែកឯក្នុងឆ្នាំ២០១០ មានមេធាវីធ្វើការពេញម៉ោងត្រឹមតែ ២៣នាក់ ក្នុងចំណោម ៩០នាក់ បានធ្វើការតាមបណ្តាខេត្តក្នុងប្រទេសកម្ពុជា (ស្មើនឹង២៦ភាគរយ)។ ទន្ទឹមនឹងនេះ ក៏មានការលំបាកមួយចំនួនសំរាប់វាស់វែងអំពីចំនួនមេធាវីដែលចូលរួមនៅក្នុងគម្រោងជំនួយផ្នែកច្បាប់ ដែលគ្រប់គ្រងដោយក្រុមមេធាវីឥតព្រំដែនប្រទេសបារាំង។

របកគំហើញ ដែលបានរៀបរាប់ខាងលើផ្តល់នូវសេចក្តីសន្និដ្ឋានជាបឋមមួយចំនួន។ ចំណុចទីមួយ សមត្ថភាពនៃសេវាកម្មជំនួយផ្នែកច្បាប់ ដែលគ្រប់គ្រងតាមរយៈ ឬ ក្នុងកិច្ចសហប្រតិបត្តិការជាមួយនឹងគណៈមេធាវី បានកើនឡើងគួរឱ្យកត់សំគាល់ តួយ៉ាងៈ សមត្ថភាពការងារពេញម៉ោងនៅនាយកដ្ឋានការពារជនក្រីក្រ កើនឡើងជាងពីរដង ហើយសមត្ថភាពការងារមិនពេញម៉ោងក៏ត្រូវបានបំពេញបន្ថែមផងដែរ ជាពិសេសតាមរយៈ គម្រោងជំនួយផ្នែកច្បាប់ ដែលគ្រប់គ្រងដោយសមាគមមេធាវីឥតព្រំដែននៃប្រទេសបារាំង (ASF)។ គំរោងថ្មីនេះ ក៏បានជួយបំពេញខ្លះៗ ទៅលើគម្លាតតំរូវការមេធាវីគ្រប់ដណ្តប់នៅទីតាំងខេត្តមួយចំនួន ដើម្បីឱ្យមាននូវសេវាកម្មជំនួយផ្នែកច្បាប់ទាំងនេះ។ ទោះបីជាយ៉ាងណាក៏ដោយ ការបំពេញនៅតាមតំបន់ទីតាំងភូមិសាស្ត្រទាំងនេះបានត្រូវប៉ះពាល់ខ្លះៗដែរ ដោយសារការថយចុះនូវវត្តមាននៃអង្គការមិនមែនរដ្ឋាភិបាលជំនួយផ្នែកច្បាប់មួយចំនួនតាមខេត្តមួយចំនួន។

ចំណុចទីពីរ គឺថា ទោះបីជាសមត្ថភាពរបស់អង្គការមិនមែនរដ្ឋាភិបាលជំនួយផ្នែកច្បាប់បង្ហាញនៅលើកដំបូងមានលក្ខណៈហាក់ដូចនៅរក្សាកំរិតដដែល បើប្រៀបធៀបនឹងឆ្នាំ២០០៦ ក៏ដោយ ក៏ប៉ុន្តែប្រសិនបើយើងពិនិត្យមើលឱ្យជិតដល់បន្តិច យើងឃើញថា សមត្ថភាពនេះបានថយចុះគួរឱ្យកត់សំគាល់ បើប្រៀបធៀបនឹងឆ្នាំ២០០៨ និង ឆ្នាំ២០០៩ ដែលអង្គការមិនមែនរដ្ឋាភិបាលទាំងនេះមានសមត្ថភាពច្រើនជាងនេះ ឧទាហរណ៍ខ្លះៗនឹងអាចជួយបង្ហាញពីការថយចុះដោយមើលជាក់ស្តែងទៅលើសមត្ថភាពរបស់អង្គការជំនួយផ្នែកច្បាប់នីមួយៗ ដូចជាៈ អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP) (នៅឆ្នាំ២០០៨ៈ មានមេធាវីចំនួន៣១នាក់ => នៅឆ្នាំ២០១០ៈ មានមេធាវីតែចំនួន២២ នាក់ប៉ុណ្ណោះ), អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC) (នៅឆ្នាំ២០០៩ៈ មានមេធាវីចំនួន៤៣នាក់ => នៅឆ្នាំ២០១០ៈ មានមេធាវីតែចំនួន២៧នាក់) ចំណែកឯ

អង្គការការពារយុត្តិធម៌កុមារ (PJJ) (នៅឆ្នាំ២០០៨: មានមេធាវីចំនួន៨នាក់ => នៅឆ្នាំ២០១០:មានមេធាវីតែចំនួន ៤នាក់ប៉ុណ្ណោះ)។

ចំណុចទីបី ដោយសារតែផលវិបាកនៃកង្វះថវិការដូចដែលបានរៀបរាប់ខាងលើ មានអង្គការជំនួយផ្នែកច្បាប់មួយចំនួនបានបិទការិយាល័យខេត្តដែលចំណាយខ្ពស់របស់ខ្លួនកាលពីកំឡុងពេលពីរឆ្នាំមុននេះ ឬ ផ្លាស់មេធាវីប្រចាំខេត្តដែលបិទការិយាល័យទាំងនោះមកធ្វើការនៅភ្នំពេញវិញ ឧទាហរណ៍: អង្គការ CDP បានបិទការិយាល័យនៅខេត្តកំពង់ចាម ក្រចេះ និងកំពង់ធំ, អង្គការ LAC បានបិទការិយាល័នៅខេត្តព្រះសីហនុ កោះកុង និង សៀមរាប, អង្គការ LSCW បានបិទការិយាល័យខេត្តកំពត និងព្រៃវែង ហើយ អង្គការ PJJ បានបិទសាខាខេត្តបាត់ដំបង បន្ទាយមានជ័យ និង សៀមរាប។ ហេតុដូច្នេះហើយ វត្តមាននៃអង្គការជំនួយផ្នែកច្បាប់តាមខេត្តទាំងអស់បានថយចុះ ហើយឥឡូវនេះ គឺថាការងារទាំងនេះត្រូវបានធ្វើដោយមេធាវីដែលធ្វើការងារនៅទីក្រុងភ្នំពេញ ដោយត្រូវធ្វើដំណើរចុះទៅខេត្តណា ដែលបានជ្រើសរើស ដើម្បីផ្តល់សេវាកម្មផ្នែកច្បាប់ក្នុងតំបន់នោះជំនួសវិញ។ មានតែការលើកលែងដ៏គួរកត់សំគាល់មួយប៉ុណ្ណោះខុសពីនិន្នាការថយចុះបែបនេះ គឺថា មានការបើកការិយាល័យថ្មីៗតាមបណ្តាខេត្តមួយចំនួន តាមរយៈអង្គការជំនួយផ្នែកច្បាប់ថ្មីមួយ ដែលគេស្គាល់ថាជា អង្គការស្ពានយុត្តិធម៌អន្តរជាតិ (IBJ)។

## ២.១.២-ចំនួនរឿងក្តីសំរាប់អ្នកផ្តល់ជំនួយផ្នែកច្បាប់នីមួយៗ

បញ្ហាប្រឈមធំបំផុតបានកើតឡើង គឺទាក់ទិននឹងការប្រមូលទិន្នន័យជាក់លាក់ពាក់ព័ន្ធនឹងចំនួនរឿងក្តីប្រចាំឆ្នាំ នៃអ្នកផ្តល់ជំនួយផ្នែកច្បាប់នីមួយៗ។ មានអង្គការតែមួយចំនួនតូចប៉ុណ្ណោះ ដែលមានប្រព័ន្ធកណ្តាលមួយសំរាប់គ្រប់គ្រងរឿងក្តី ឬ បញ្ចូលក្នុងកំព្យូទ័រ (ប្រព័ន្ធគ្រប់គ្រងទិន្នន័យ) ដែលជាហេតុធ្វើឱ្យមានការលំបាក ដើម្បីទទួលបាននូវទិន្នន័យជាក់លាក់នៅក្នុងរយៈពេលដ៏ខ្លី។ លើសពីនេះទៀត មិនមែនសុទ្ធតែអង្គការទាំងអស់ប្រមូលទិន្នន័យប្រភេទដូចគ្នានោះទេ (ពោលគឺ ដូចជា: រឿងក្តីបើកថ្មីដែលសល់ពីឆ្នាំមុនៗ, រឿងក្តីថ្មីៗក្នុងទទួលបានក្នុងមួយឆ្នាំៗ, រឿងក្តីដែលបានជំនុំជម្រះហើយ និងរឿងក្តីដែលបានបិទបញ្ចប់) ឬ មូលដ្ឋានពេលតែមួយដូចគ្នានោះទេ (ពោលគឺ មូលដ្ឋានប្រចាំឆ្នាំ) ដែលនាំឱ្យពិបាកធ្វើការប្រៀបធៀបទិន្នភាពជារួម។ អង្គការមួយចំនួនទៀតមិនមានទិន្នន័យជាក់លាក់ក្នុងដៃ (ក្នុងពេលសំភាន៍) ដូច្នេះ ហើយគេបានត្រឹមតែផ្តល់នូវចំនួនប៉ាន់ប្រមាណនៃចំនួនរឿងក្តីប្រចាំឆ្នាំរបស់អង្គការបានធ្វើតែប៉ុណ្ណោះ។ ដូចនេះ ការប្រៀបធៀបដែលបានបង្ហាញក្នុងរបាយការណ៍នេះ គួរតែត្រូវបានចាត់ទុកត្រឹមតែជាការបង្ហាញពីសមត្ថភាពប្រចាំឆ្នាំនៃអ្នកផ្តល់ជំនួយផ្នែកច្បាប់ទាំងអស់តែប៉ុណ្ណោះ។

ម្យ៉ាងទៀត ក្រុមអ្នកផ្តល់ជំនួយផ្នែកច្បាប់នីមួយៗក៏មានយុទ្ធសាស្ត្រ និងវិធីសាស្ត្រផ្សេងៗពីគ្នាផងដែរ។ អង្គការខ្លះផ្តោតទៅលើតែរឿងក្តីធំៗប៉ុណ្ណោះ (តួយ៉ាង: អង្គការ CLEC និង អង្គការ LICADHO) ឯអង្គការផ្សេងទៀតធ្វើការទៅលើរឿងក្តីតូចៗដែលពាក់ព័ន្ធនឹងក្រុមជន ងាយរងគ្រោះ (ដូចជា: អង្គការ PJJ និង អង្គការ LSCW) ចំណែកអង្គការខ្លះទៀត គឺជាអង្គការសិទ្ធិមនុស្ស និងមានត្រឹមតែកម្មវិធីជំនួយផ្នែកច្បាប់តូចមួយ បន្ថែមទៅលើសកម្មភាពផ្សេងៗរបស់ខ្លួន

(ឧទាហរណ៍: អង្គការ ADHOC អង្គការ LICADHO និង អង្គការ CWCC), អង្គការដទៃទៀតមានឯកទេសកម្មការពារសិទ្ធិជនជាប់ចោទប៉ុណ្ណោះ (អង្គការ IBJ) ហើយអ្នកផ្តល់ជំនួយផ្នែកច្បាប់ខ្លះទៀត ធ្វើការចំបងតែទៅលើករណីណាដែលតុលាការបញ្ជូនឱ្យប៉ុណ្ណោះ (ដូចជា: សមាគមមេធាវីតតព្រំដែនប្រទេសបារាំង ASF-BAKC និងនាយកដ្ឋានការពារជនក្រីក្រនៃគណៈមេធាវី BAKC-LAD)។ ដូចនេះ ការប្រៀបធៀបនៃចំនួនរឿងក្តីពីអង្គការមួយទៅអង្គការមួយ គឺជារឿងលំបាក ហើយម្យ៉ាងទៀតចំនួននៃរឿងក្តីទាំងអស់ ក៏មិនបានឆ្លុះបញ្ចាំងចាំបាច់ទៅលើចំនួនការងារ ដែលអង្គការនីមួយៗបានធ្វើដែរ ឧទាហរណ៍ អង្គការ CLEC បានលើកឡើងថា គ្មានរឿងក្តីរបស់ខ្លួន ដែលមានកូនក្តីតិច ជាង៥០នាក់នោះទេ។ ចំណុចនេះត្រូវតែចាំបាច់ពិចារណាជាមុន នៅពេលដែលយើងមើលអំពីចំនួនរឿងក្តីជំនួយផ្នែកច្បាប់ ផ្តល់ដោយអង្គការនីមួយៗ (តារាងទី២)។

**<u>តារាង២: ចំនួននៃរឿងក្តីជំនួយផ្នែកច្បាប់សំរាប់អ្នកជំនួយផ្នែកច្បាប់នីមួយៗក្នុងឆ្នាំ២០០៩</u>**

(រឿងក្តីថ្មីៗក្នុងមួយឆ្នាំ ក្រៅពីរឿងក្តីកំពុងចាត់ការ)

| ឈ្មោះអ្នកផ្តល់ជំនួយផ្នែកច្បាប់ | ចំនួន |
|---|---|
| សមាគម ADHOC | 24 |
| អង្គការ ASF-BAKC* | មិនមានទិន្នន័យជាក់លាក់ |
| នាយកាដ្ឋានការពារជនក្រីក្រ BAKC-LAD | 802 |
| អង្គការ CDP | 553 |
| អង្គការ CLEC | 13 |
| អង្គការ CWCC | 270 |
| អង្គការ IBJ | 320 |
| អង្គការ LAC | 1,628 |
| អង្គការ LICADHO | 52 |
| អង្គការ LSCW | 279 |
| អង្គការ PJJ | 393 |

** នៅឆ្នាំ ២០០៩ មិនមានដំណើរការទេ ប៉ុន្តែចំនួនទទួលបានជាមធ្យមពីឆ្នាំ២០០៦ ដល់ពី ២០០៨ ពី ៧២០ ដល់ ១២០០ ករណី។*

**<u>ចំនួននៃរឿងក្តីជំនួយផ្នែកច្បាប់ក្នុងមួយអង្គការៗ នៅឆ្នាំ២០០៩</u>**




## ២.១.៣-ប្រភេទរឿងក្តីជំនាញ និងឯកទេសកម្មនៃអ្នកផ្តល់ជំនួយផ្នែកច្បាប់

អ្នកផ្តល់ជំនួយផ្នែកច្បាប់ភាគច្រើន (ប្រហែល ៧០ភាគរយ) បានបន្តផ្តោតលើរឿងក្តីព្រហ្មទណ្ឌ ដោយរឿងក្តីរដ្ឋប្បវេណីមានអាទិភាពទាបជាង (ប្រហែល ៣០ភាគរយ)។ បទសម្ភាសន៍ជាមួយនឹងអ្នកផ្តល់ជំនួយផ្នែកច្បាប់ បានឱ្យដឹងពីទិន្នាការផ្សេងមួយទៀត ជារួម គឺថា មកត្រឹមឆ្នាំ២០១០ សមត្ថភាពសំរាប់សេវាកម្មផ្នែកច្បាប់ទូទៅមានតិចតួចជាងប្រៀបធៀបនឹងព័ត៌មានដែលប្រមូលបានសំរាប់ការស្ទង់មតិឆ្នាំ២០០៦។ ម្យ៉ាងវិញទៀត សមត្ថភាពសំរាប់សេវាកម្មផ្នែកច្បាប់សំរាប់ឯកទេសកម្មមានការកើនឡើង ជាពិសេសរឿងក្តីពាក់ព័ន្ធនឹងបញ្ហាស្ត្រី កុមារ និងជនរងគ្រោះដោយការជួញដូរ, ការរំលោភសេពសន្ថវៈ និងការធ្វើអាជីវកម្មផ្លូវភេទ (សូមមើលក្រាហ្វិក)។ ថ្វីត្បិតតែមានអ្នកផ្តល់ជំនួយផ្នែកច្បាប់មួយចំនួនមានឯកទេសកម្មលើបញ្ហាទាំងនេះរួចហើយនៅឆ្នាំ២០០៦ (ពោលគឺ អង្គការ CWCC, អង្គការ PJJ និង អង្គការ LSCW) ក៏និន្នាការនេះត្រូវបានពង្រឹងបន្ថែមទៀត ដោយកម្មវិធីឯកទេសកម្មថ្មីដែលផ្តល់ដោយអ្នកផ្តល់ជំនួយផ្នែកច្បាប់ទូទៅ ដែលមានស្រាប់ ដូចជា អង្គការ LAC និង អង្គការ CDP។ មានតែអង្គការ IBJ ប៉ុណ្ណោះ ដែលជាអ្នកផ្តល់ជំនួយផ្នែកច្បាប់មួយដែលមានឯកទេសកម្មសំរាប់រឿងក្តីពាក់ព័ន្ធនឹងជនជាប់ចោទ។ ទាក់ទិននឹងការប្រែប្រួលនិន្នាការនេះ ត្រូវបានអង្គការជំនួយផ្នែកច្បាប់មួយចំនួន ពន្យល់ថា ដោយសារតែមានការអំពាវនាវឱ្យដាក់សំណើគំរោង (call for proposals) ប៉ុន្មានឆ្នាំថ្មីៗរបស់ម្ចាស់ជំនួយជាច្រើនសំរាប់គំរោង “សិទ្ធិទទួលបានយុត្តិធម៌ទូទៅ” មានតិចជាងគំរោងដែលផ្តោតលើក្រុមដែលងាយរងគ្រោះដែលបានកើនឡើង ដូចជាៈ ពាក់ព័ន្ធបញ្ហាស្ត្រី កុមារ និង ជនរងគ្រោះនៃការជួញដូរ និងការរំលោភសេពសន្ថវៈ។ ជាលទ្ធផល អង្គការដែលផ្តល់ជំនួយផ្នែកច្បាប់ទូទៅ បានកែសំរួលសកម្មភាពរបស់ខ្លួនឆ្ពោះទៅរក*កម្មវិធីឯកទេសកម្ម* វិញក្នុងគោលបំណងរក្សាសមត្ថភាពរបស់ខ្លួន។

ទោះបីជាការរីកចំរើននេះហាក់ដូចជាបានធ្វើឱ្យសេវាកម្មជំនួយផ្នែកច្បាប់ មានលក្ខណៈល្អប្រសើរឡើងសំរាប់ក្រុមងាយរងគ្រោះដែលជាសមិទ្ធិផលមួយដ៏ធំក៏ដោយ ប៉ុន្តែទន្ទឹមនឹងនេះ វាក៏ធ្វើឱ្យមានគម្លាតធំមួយសំរាប់ការរកឱ្យបាននូវ

*សេវាកម្មជំនួយផ្នែកច្បាប់ទូទៅ* ផងដែរ។ ជាមួយនឹងបញ្ហានេះ អង្គការជំនួយផ្នែកច្បាប់ជាច្រើនបានរាយការណ៍ពីរបៀបដែលពួកគេត្រូវកាត់បន្ថយសំណើសុំឱ្យការពារក្តីជាច្រើនពីសំណាក់ប្រជាពលរដ្ឋក្រក្រីដែលមកការិយាល័យរបស់ខ្លួន។

តំរូវការបន្ទាន់ភាគច្រើន ជាពិសេស ពាក់ព័ន្ធនឹងរឿងដីធ្លី និងការបណ្តេញចេញ ដែលមានលក្ខណៈធំៗហាក់បីដូចជាត្រូវបានបំពេញដោយថវិកាសំរាប់ឯកទេសកម្មពិសេសមួយចំនួនសំរាប់ប្រើប្រាស់ ដើម្បីការពារក្តីឱ្យប្រជាពលរដ្ឋ ដែលរងផលប៉ះពាល់ (ពោលគឺៈ អង្គការ LAC និង អង្គការ CLEC)។




**២.២_ទស្សនៈស្តីពីបញ្ហាប្រឈម និងទស្សនៈចំពោះជំនួយផ្នែកច្បាប់ក្នុងប្រទេសកម្ពុជាសំរាប់ពេលអនាគត**

សំនួរចុងក្រោយនៃបទសម្ភាសន៍ បានផ្តោតទៅលើទស្សនៈរបស់អ្នកឆ្លើយអំពីជំនួយផ្នែកច្បាប់ក្នុងប្រទេសកម្ពុជាសំរាប់ពេលអនាគត។ សំនួរ គឺថា “*តើអ្នកគិតយ៉ាងដូចម្តេចចំពោះភាពចាំបាច់នានា ដែលត្រូវធ្វើទៅពេលអនាគត ដើម្បីធ្វើឱ្យស្ថានភាពនៃជំនួយផ្នែកច្បាប់ក្នុងប្រទេសកម្ពុជាមានលក្ខណៈប្រសើរឡើង?*” នៅពេលផ្តល់ចម្លើយរបស់ពួកគេ អ្នកឆ្លើយភាគច្រើនបាននិយាយជាដំបូងអំពីប្រឈមបច្ចុប្បន្ននានា មុននឹងធ្វើការផ្តល់អនុសាសន៍លើកំណែទម្រង់សំរាប់ពេលអនាគត។

**(ក) បញ្ហាប្រឈមសំរាប់ការផ្តល់សេវាកម្មជំនួយផ្នែកច្បាប់ (មេធាវី)**

ខាងក្រោមនេះ គឺជាកំរងនៃប្រឈមជាក់ស្តែងនានាចំពោះការផ្តល់សេវាកម្មជំនួយផ្នែកច្បាប់ ឱ្យមានប្រសិទ្ធិភាពក្នុងប្រទេសកម្ពុជាសព្វថ្ងៃ ដែលត្រូវបានលើកឡើងនៅក្នុងពេលធ្វើកិច្ចសម្ភាសន៍:

*កំរិតនៃការយល់ដឹងនៅទាបក្នុងចំណោមប្រជាពលរដ្ឋទូទៅ:* ប្រជាពលរដ្ឋភាគច្រើនមិនបានដឹងអំពីសិទ្ធិរបស់ពួកគេ និងមិនបានធ្វើឱ្យយល់ដឹងពីរបៀបនៃការទទួលបានសេវាកម្មផ្នែកច្បាប់ ក៏ដូចជា ខ្វះការជឿទុកចិត្តទៅលើប្រព័ន្ធតុលាការ។

*ស្ថាប័នតុលាការ* : ការយល់ដឹងតិចតួចក្នុងចំណោមមន្ត្រីតុលាការអំពីតួនាទី និងការទទួលខុសត្រូវការស៊ើបអង្កេតមិនគ្រប់គ្រាន់នៃរឿងក្តីជាញឹកញាប់តំរូវឱ្យមេធាវីអនុវត្តន៍ការស៊ើបអង្កេតដោយខ្លួនឯង (មានតែមេធាវីតិចតួចប៉ុណ្ណោះ ដែល

មានថវិកាសំរាប់ស៊ើបអង្កេត លើកលែងតែមេធាវីដែលធ្វើការនៅអង្គការសិទ្ធិមនុស្សប៉ុណ្ណោះ ដែលអាចពឹងផ្អែកលើផ្នែកស៊ើបអង្កេតរបស់ខ្លួន), ការយល់ដឹងតិចតួចពាក់ព័ន្ធនឹងអំពើហឹង្សាផ្លូវភេទ, ភាពឯករាជ្យមិនពេញលេញរបស់គណៈមេធាវី ។

*អំពើពុករលួយក្នុងតុលាការ និងក្នុងចំណោមមន្ត្រីប្រតិបត្តិច្បាប់* : មេធាវីបានចំណាយពេលវេលាច្រើនក្នុងការទំនាក់ទំនងជាមួយក្រឡាបញ្ជី ដើម្បីកុំឱ្យពួកគេទទួលយកលុយក្រៅបន្ថែមសំរាប់ទទួលបានរឿងក្តី ឬសំរាប់យករឿងក្តីទៅជំនុំជម្រះ (ឬ សំរាប់ពន្លឿនដំណើរជំនុំជម្រះរឿងក្តី) ។

*កង្វះសមត្ថភាព និងមេធាវី:* ស្ទើរតែអង្គការទាំងអស់រាយការណ៍ថា ពួកគេមិនអាចដោះស្រាយគ្រប់រឿងក្តីទាំងអស់ ដែលពួកគេបានទទួលទេ, តំរូវការច្រើនជាងសមត្ថភាពដែលមាន, កង្វះមេធាវី (ជាញឹកញាប់ ក៏មានពាក់ព័ន្ធនឹងគោលនយោបាយនៃការទទួលរឿងក្តីមានលក្ខណៈរឹតត្បិតដោយគណៈមេធាវី), ភាពលំបាកក្នុងការរក្សាទុកនូវមេធាវីដែលមានលក្ខណៈសម្បត្តិល្អឱ្យនៅធ្វើការតាមបណ្តាខេត្តនានា, កង្វះខាតច្រើនអំពីសេវាកម្មជំនួយផ្នែកច្បាប់ផ្នែកទូទៅនៅក្នុងប្រទេសកម្ពុជា (គឺដោយសារតែអ្នកផ្តល់សេវាកម្មធំបំផុតចំនួនបី គឺ អង្គការ LAC, នាយកដ្ឋានការពារជនក្រីក្ររបស់គណៈមេធាវី BACK-LAD, អង្គការ CDP, និងគម្រោងរបស់សមាគមមេធាវីឥតព្រំដែននៃប្រទេសបារាំង ដែលទើបតែបានចាប់ផ្តើមសារជាថ្មីឡើងវិញ) ។

*ប្រសិទ្ធភាពក្នុងការផ្តល់ជំនួយផ្នែកច្បាប់* : ជាពិសេស អង្គការសិទ្ធិមនុស្សលើកការព្រួយបារម្ភជុំវិញប្រសិទ្ធភាព និងលក្ខណៈសម្បត្តិរបស់មេធាវីជំនួយផ្នែកច្បាប់, ជានិច្ចកាល មេធាវីតែងតែមិនសូវត្រៀមលក្ខណៈការពាររឿងក្តីរបស់គេឱ្យបានពេញលេញ ហើយមេធាវីភាគច្រើនមិនបានចុះមើល ឬផ្តល់ព័ត៌មានដល់កូនក្តីរបស់ខ្លួននៅមុនពេលសវនាការ ឬនៅក្នុងពន្ធនាគារ (ដោយសារតែ ជាញឹកញាប់បញ្ហានេះអាចបណ្តាលមកពីធនធានមានកំណត់), ប្រព័ន្ធគ្រប់គ្រងព័ត៌មានក្នុងចំណោមអ្នកផ្តល់ជំនួយផ្នែកច្បាប់នៅមិនទាន់មានលក្ខណៈពេញលេញ, កង្វះខាតការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈមេធាវីឱ្យបានត្រឹមត្រូវ ។

*កង្វះការផ្តល់ថវិកាឱ្យបានគ្រប់គ្រាន់ និងយូរអង្វែង* : ស្ទើរតែអ្នកផ្តល់ជំនួយផ្នែកច្បាប់ទាំងអស់បានចាត់ទុកកង្វះថវិកាជាបញ្ហាប្រឈមចំបងមួយ, ភាគច្រើនថវិកាទទួលបានសំរាប់គំរោងរយៈពេលខ្លី (ជាញឹកញាប់ គឺថវិកាសំរាប់ត្រឹមតែមួយឆ្នាំ)សំរាប់បំរើឱ្យតំរូវការជំនួយផ្នែកច្បាប់ដែលមានរយៈពេលវែង (មានរឿងក្តីជាច្រើនត្រូវការចំណាយពេលយូរជាងមួយឆ្នាំទៅទៀត), ជាទូទៅមានកំរិតប្រាក់ខែទាបសំរាប់បុគ្គលិកបំរើការលើវិស័យជំនួយផ្នែកច្បាប់, ការការចាកចេញរបស់បុគ្គលិកជាបញ្ហាប្រឈមមួយ (ដោយសារតែការងារនៅផ្នែកឯកជន ជាទូទៅទទួលបានលក្ខខណ្ឌល្អជាងនៅអង្គការមិនមែនរដ្ឋាភិបាល), លក្ខខណ្ឌតំរូវផ្លូវការនៃសំណើគំរោង (proposals) របស់ម្ចាស់ជំនួយ (ប្រាក់បៀវត្សបុគ្គលិក/ ថវិកាស្នូល/ សកម្មភាព) មិនឆ្លើយតបទៅនឹងចរិកលក្ខណៈរបស់សេវាកម្មជំនួយផ្នែកច្បាប់ ។

### (ខ) ប្រសិទ្ធភាពនៃជំនួយផ្នែកច្បាប់: តំរូវការឱ្យមានការវាយតម្លៃ និងការតាមដានបន្ថែម

ជាពិសេស អង្គការសិទ្ធិមនុស្សដែលបញ្ជូនរឿងក្តី ដែលបានស៊ើបអង្កេតទៅឱ្យអង្គការជំនួយផ្នែកច្បាប់បានរាយការណ៍នូវការវាយតម្លៃចំរុះមួយអំពីគុណភាពនៃមេធាវីជំនួយផ្នែកច្បាប់ ។ ជាទូទៅ បទសម្ភាសន៍បានប្រាប់ឱ្យដឹងពីកង្វះខាតនៃការដឹងអំពីការអនុវត្ត និងលទ្ធផលនៃសេវាកម្មជំនួយផ្នែកច្បាប់ ។ ហេតុដូច្នេះ អ្នកឆ្លើយមួយចំនួនបានទទូចសុំឱ្យមានការតាមដានបន្ថែមទៅលើសេវាកម្មជំនួយផ្នែកច្បាប់ រួមបញ្ចូលទាំងការពេញចិត្តរបស់កូនក្តីទៅលើគុណភាពសេវាកម្មនោះ

ផងដែរ។ វិធីសាស្ត្រជាច្រើន ដែលបង្កើនការវាយតម្លៃនៃសេវាកម្មជំនួយផ្នែកច្បាប់ ត្រូវតែធ្វើឱ្យមានតុល្យភាពនឹងតំរូវការជាក់ស្តែង ពីព្រោះថា ធ្វើដូច្នេះវានឹងមិនផ្តល់ការងារបន្ថែមសំរាប់អ្នកផ្តល់សេវាកម្មជំនួយផ្នែកច្បាប់ ដែលកំពុងមានបន្ទុកធ្ងន់ស្រាប់ហើយនោះទេ។ អ្នកផ្តល់សេវាកម្មជំនួយផ្នែកច្បាប់ ដែលមានស្រាប់មួយចំនួនមានប្រព័ន្ធតាមដានរបស់ខ្លួនរួចជាស្រេចហើយ។ ដូចនេះ យន្តការតាមដានបែបនេះ គួរតែពង្រីកបន្ថែមទៅដល់តួអង្គផ្សេងៗទៀត ដូចជា អង្គការមិនមែនរដ្ឋាភិបាលណាដែលពុំទាន់មានប្រព័ន្ធតាមដាននេះ និងក្រុមមេធាវីឯកជនដែលការពារក្តីជំនួយផ្នែកច្បាប់ ឬ គណៈមេធាវីជាដើម។ ទាំងនេះត្រូវតែមានទំនាក់ទំនងដោយផ្ទាល់ផងដែរពីក្រុមអ្នកទទួលប្រយោជន៏នៃសេវាកម្មជំនួយផ្នែកច្បាប់។ ជារួមមក ការមានប្រព័ន្ធតាមដានមួយត្រឹមត្រូវអាចជួយដោះស្រាយគុណភាពសេវាកម្មមេធាវី ដែលមានបច្ចុប្បន្នឱ្យកាន់តែល្អប្រសើរឡើង ក៏ដូចជា ទន្ទឹមនឹងនោះ វានឹងជួយធានាឱ្យមានកំរិតនៃគុណភាពល្អ និងក្រមសីលធម៌វិជ្ជាជីវៈល្អនៅក្នុងការផ្តល់សេវាកម្មទាំងនេះ។

**(គ) ការបង្កើនសមត្ថភាព និងធនធានសំរាប់សេវាកម្មជំនួយផ្នែកច្បាប់**

អ្នកឆ្លើយសំនួរភាគច្រើនបានសំដែងអារម្មណ៏ថា មានគម្លាតធំមួយនៅក្នុងសមត្ថភាពជំនួយផ្នែកច្បាប់ ហើយសេចក្តីត្រូវការសេវាកម្មទាំងនេះនៅទីក្រុងភ្នំពេញ និងនៅតាមបណ្តាខេត្តជាច្រើនវាលើសពីធនធាន ដែលមាននាពេលបច្ចុប្បន្ន។ អត្រាមេធាវីសំរាប់ការពារភូមិស្រុកមួយនៅក្នុងប្រទេសកម្ពុជា នៅមានកំរិតទាបនៅឡើយ ហើយសមត្ថភាពជំនួយផ្នែកច្បាប់ដែលមានស្រាប់ និងមានសក្តានុពល ភាគច្រើន បានផ្តោតតែទៅលើតំបន់ទីប្រជុំជន ឬធ្វើការឯកជន។ អ្នកឆ្លើយខ្លះបានផ្តល់មតិថា សមត្ថភាពទាបក៏អាចបណ្តាលមកពីចំនួនមេធាវី ដែលត្រូវបានជ្រើសរើសយកបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី និងនៅគណៈមេធាវីមានចំនួនតិច គឺប្រហែលតែមេធាវី ៥0នាក់ ប៉ុណ្ណោះ សំរាប់ការបណ្តុះបណ្តាលរៀងរាល់ឆ្នាំ ដែលចំនួននេះតិចជាង ១0ដង នៃចំនួននិស្សិតបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យច្បាប់ក្នុងប្រទេសកម្ពុជា ក្នុង១ឆ្នាំៗទៅទៀត។ អ្នកឆ្លើយសំនួរមួយរូបបានត្អូញត្អែរថា ដោយសារតែបញ្ហានេះ មាននិស្សិតច្បាប់បញ្ចប់ការសិក្សាជាច្រើនបាន "ធ្លាក់ខ្លួនក្លាយទៅជាអ្នកបើកម៉ូតូកង់" ដែលនេះ គឺជាការខកខានក្នុងការប្រើប្រាស់នូវធនធានដ៏មានសក្តានុពលមួយចំនួនធំ។ ហេតុដូចនេះ អ្នកឆ្លើយលើសលុបបានស្នើឱ្យប្រើប្រាស់នូវធនធាននិស្សិតច្បាប់ ដែលបញ្ចប់ការសិក្សាថ្មីៗទាំងនេះឱ្យមានប្រយោជន៏ ឧទាហរណ៏ជាទម្រង់នៃសេវាកម្មជំនួយផ្នែកច្បាប់ចំរុះ (Para-legal Services) ឬ ឱ្យចូលរួមការងារជំនួយផ្នែកច្បាប់ពីដំបូងតាមរយៈការធ្វើការកម្មសិក្សាផ្នែកច្បាប់ និងការបណ្តុះបណ្តាលជាមេធាវី។ មេធាវីក្មេងៗត្រូវការអនុវត្តជាក់ស្តែងដែលអាចឆ្លើយតបជាមួយតំរូវការសេវាកម្មបែបនេះនៅតាមសហគមន៏។ លើសពីនេះ ជំនួយផ្នែកច្បាប់មិនមែនគ្រាន់តែជាការតំណាងឱ្យកូនក្តីនៅក្នុងតុលាការប៉ុណ្ណោះទេ ប៉ុន្តែវាក៏អាចពាក់ព័ន្ធនឹងការផ្តល់យោបល់ផ្នែកច្បាប់, ការសំភាសន៏ និងការត្រៀមលក្ខណៈជាមួយសាក្សី, ការជួយដាក់ពាក្យបណ្តឹង និងកិច្ចការផ្សេងៗទៀតផងដែរ។ ភាគច្រើននៃកិច្ចការទាំងនេះ អាចបានធ្វើដោយនិស្សិតច្បាប់ដែលបញ្ចប់ការសិក្សាថ្មីៗ ដែលពួកគេក៏អាចយល់ដឹងពីកិច្ចការជំនួយផ្នែកច្បាប់ផ្សេងៗទៀតក្នុងពេលតែមួយបានដែរ។ ការសាកល្បងការងារផ្នែកច្បាប់នៅតាមសហគមន៏ ក៏ជារឿងសំខាន់ផងដែរ (ឧទាហរណ៏ នាំនិស្សិតច្បាប់ថ្មីៗទាំងនេះឱ្យទៅចុះជួយប្រជាសហគមន៏នៅខេត្តរតនៈគីរី ជាដើម")។ មានសំណើផ្សេងទៀត ដែលថាទំរង់ជំនួយផ្នែកច្បាប់ផ្សេងទៀតក៏អាចបង្កើតឡើង តាមរយៈកិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យច្បាប់នៅក្នុងប្រទេសកម្ពុជាតែម្តង។ ដើម្បីធ្វើឱ្យវិធីសាស្ត្របែបនេះទទួលបានជោគជ័យ ជំនួយផ្នែកច្បាប់ គួរត្រូវបានដាក់

បញ្ចូលក្នុងកម្មវិធីសិក្សាច្បាប់ និងការបណ្តុះបណ្តាលមេធាវីផងដែរ។ អនុសាសន៍បែបនេះមិនត្រឹមតែសំរាប់នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីទេ ប៉ុន្តែវាក៏មានរួចស្រេចទៅហើយ នៅតាមសាកលវិទ្យាល័យមួយចំនួន។

អ្នកផ្តល់ជំនួយផ្នែកច្បាប់ទាំងអស់ បានទទួលស្គាល់ថា កំរិតនៃថវិកាសំរាប់សេវាកម្មជំនួយផ្នែកច្បាប់បច្ចុប្បន្ន គឺនៅខ្វះខាតយ៉ាងខ្លាំង ហើយរចនាសម្ព័ន្ធនៃថវិកាសំរាប់សេវាកម្មជំនួយផ្នែកច្បាប់ក្នុងប្រទេសកម្ពុជា បច្ចុប្បន្ន គឺមិនអាចស្ថិតស្ថេរយូរអង្វែងទេ។ បច្ចុប្បន្ននេះថវិកាសំរាប់ជំនួយផ្នែកច្បាប់ ភាគច្រើន បានមកពីម្ចាស់ជំនួយអន្តរជាតិ ចំណែកឯរាជរដ្ឋាភិបាលកម្ពុជា បាននឹងកំពុងតែធ្វើវិភាគទានប្រហែលចំនួន ៥០,០០០ ដុល្លារសហរដ្ឋអាមេរិក ប៉ុណ្ណោះក្នុងមួយឆ្នាំៗ ។ ដូចនេះ មានការទទួលស្គាល់ជាទូទៅមួយក្នុងចំណោមអ្នកឆ្លើយ ដែលថា វិភាគទានរបស់រាជរដ្ឋាភិបាលកម្ពុជាចាំបាច់ត្រូវបង្កើនឱ្យច្រើនជាងនេះ សំរាប់ពេលអនាគត ដើម្បីធ្វើឱ្យមជំនួយផ្នែកច្បាប់ស្ថិតស្ថេរយូរ អង្វែងជាងនេះ។ កិច្ចការនេះអាចធ្វើបាន ឧទាហរណ៍តាមរយៈការកំណត់យកចេញពីថវិកាជាតិ ឬធ្វើច្បាប់ថ្មីយ៉ាងជាក់លាក់សំរាប់សេវាកម្មជំនួយផ្នែកច្បាប់។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកឆ្លើយភាគច្រើនយល់ឃើញថា ដំណើរការនេះនឹងត្រូវការពេលវេលាខ្លះ ហើយចូលរួមចំណែកវិភាគទានថវិការបស់រាជរដ្ឋាភិបាលអាចនឹងកើនឡើងជាលំដាប់សំរាប់កិច្ចការនេះ។ មតិខ្លះបានស្នើឱ្យមានបង្កើតមូលនិធិជំនួយផ្នែកច្បាប់ (ដែលមានលក្ខណៈឯករាជ្យ) ដែលអាចបញ្ចូលថវិការបស់រាជរដ្ឋាភិបាល និងម្ចាស់ជំនួយសំរាប់សេវាជំនួយផ្នែកច្បាប់។ បើត្រូវបានបង្កើត យន្តការថវិកាបែបនេះ អាចកំណត់ឱ្យមានគោលនយោបាយជាក់លាក់សំរាប់ការផ្តល់ថវិកាទៅលើសេវាកម្មជំនួយផ្នែកច្បាប់ ដែលអាចកែតម្រូវបញ្ហាខ្លះៗ ដោយភ្ជាប់នឹងការផ្តល់ថវិកាពីម្ចាស់ជំនួយអន្តរជាតិ ("ជំនួយផ្នែកច្បាប់ គឺមិនមែនជាគម្រោងតែមួយនោះទេ ក៏ប៉ុន្តែ វាគឺជាសេវាកម្មដែលមានរយៈពេលវែង!")។ សំរាប់រយៈពេលបណ្តោះអាសន្នបច្ចុប្បន្ន អ្នកឆ្លើយទាំងនេះបានសំណូមពរដល់ម្ចាស់ជំនួយឱ្យពិចារណាបង្កើនរយៈពេលនៃការផ្តល់ថវិកាសំរាប់សេវាកម្មជំនួយផ្នែកច្បាប់យ៉ាងហោចណាស់ឱ្យបានរហូតដល់រយៈពេលបីឆ្នាំ។

ជាចុងក្រោយ អ្នកឆ្លើយភាគច្រើនបានទទួលស្គាល់ថា វាចាំបាច់ណាស់ចំពោះការរុករកមធ្យោបាយថ្មីៗទៀត សំរាប់យន្តការផ្តល់ជំនួយផ្នែកច្បាប់ ដើម្បីបំពេញតំរូវការជាច្រើនក្នុងប្រទេសកម្ពុជា។ ការប្រើប្រាស់និស្សិតបញ្ចប់ការសិក្សាថ្មីៗ ក៏ជាទំរង់នៃវិធីសាស្ត្រមួយដែលត្រូវបានស្នើឡើង។ អ្នកផ្សេងទៀតបានលើកឡើងអំពីការរួមបញ្ចូលគ្នានូវការការពាររឿងក្តីឯកជនជាមួយការការពាររឿងក្តីជំនួយផ្នែកច្បាប់មួយចំនួន។ ក្រុមមេធាវីបំរើប្រយោជន៍សាធារណៈមួយចំនួន តួយ៉ាងក្រុមមេធាវីសំរិទ្ធ (Samreth Law Group) ផ្តល់ឧទាហរណ៍ជោគជ័យរួចទៅហើយ ចំពោះវិធីសាស្ត្របែបនេះ។ ដោយឡែកគណៈមេធាវីហាក់ដូចជាមានចំណាប់អារម្មណ៍ឱ្យមេធាវីរបស់ខ្លួនចូលរួមការពារក្តីជំនួយផ្នែកច្បាប់ឱ្យបានច្រើន ដោយសារតែភាគច្រើន មេធាវីទាំងនោះកំពុងធ្វើការពាររឿងក្តីឯកជន ដោយបន្ថែមរឿងក្តីជំនួយផ្នែកច្បាប់មួយចំនួន ដូចជា តាមរយៈការដាក់បទបញ្ជាថ្មីៗនៃវិជ្ជាជីវៈនេះ ជាដើម។ ទោះបីជាយ៉ាងណាក៏ដោយ យោងតាមអ្នកឆ្លើយសំនួរ ដើម្បីធានាឱ្យមានប្រសិទ្ធភាព និងគុណភាពសេវាកម្មជំនួយផ្នែកច្បាប់មេធាវី វាចាំបាច់ត្រូវការបង្កើនកំរិតនៃការតាមដាន និងការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈយ៉ាងតឹងរ៉ឹង ចំពោះមេធាវីទាំងនោះ។

(ឃ) ជំនួយផ្នែកច្បាប់ជាឧបករណ៍មួយសម្រាប់ការផ្លាស់ប្តូរ?

អ្នកឆ្លើយសំនួរជាច្រើនបានមើលឃើញថា ជំនួយផ្នែកច្បាប់មិនត្រឹមតែជាសិទ្ធិរបស់ប្រជាពលរដ្ឋក្រីក្រ និងប្រជាពលរដ្ឋងាយរងគ្រោះប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាឱកាសមួយដើម្បីលើកស្ទួយការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងប្រព័ន្ធតុលាការរបស់ប្រទេសកម្ពុជាផងដែរ។ ជាញឹកញាប់ មេធាវីជំនួយផ្នែកច្បាប់ គឺគ្រាន់តែជា "អ្នកក្រៅ" នៅតាមបណ្តាសាលាដំបូងខេត្ត និងក៏ផ្តល់ធាតុផ្សំខាងក្រៅដ៏សំខាន់ដែលចាំបាច់នៅក្នុងដំណើរការផ្លូវច្បាប់។ មានតែមេធាវីប៉ុណ្ណោះដែលអាចតស៊ូមតិ និងធ្វើឱ្យស្ថានភាពក្នុងតុលាការមានភាពល្អប្រសើរឡើង ។ អង្គការជំនួយផ្នែកច្បាប់ខ្លះបានទទួលស្គាល់ថា ពួកគេនឹងបំរើឱ្យផលប្រយោជន៍កូនក្តីរបស់គេបានល្អប្រសើរ ប្រសិនបើពួកគេបានអនុវត្តបែបនោះជាលំដាប់លំដោយ នៅក្នុងតុលាការជាពិសេស នៅតាមសាលាដំបូងខេត្តផ្សេងៗ។ ជាលទ្ធផល អង្គការជំនួយផ្នែកច្បាប់ ដូចជា អង្គការ LAC ឬ អង្គការ IBJ បានចាប់ផ្តើមបង្កើតឱ្យមានកិច្ចប្រជុំជាទៀងទាត់ និងកិច្ចពិភាក្សាតុមូលជាច្រើនជាមួយនឹងមន្ត្រីតុលាការ និងមន្ត្រីអនុវត្តន៍ច្បាប់ដទៃទៀត (ដូចជា៖ ចៅក្រម, ព្រះរាជអាជ្ញា, ក្រឡាបញ្ជី, ប៉ូលីស ។ល។) នៅតាមខេត្ត ដើម្បីពិភាក្សា, ក្នុងលក្ខណៈមិនទាន់ផ្លូវការទៅលើបញ្ហានានា ក៏ដូចជា ការអនុវត្តមិនត្រឹមត្រូវផ្សេងៗទៀត។ ជាទូទៅ អ្នកឆ្លើយដែលបានចូលរួមក្នុងការផ្លាស់ប្តូរបែបនេះរាយការណ៍ពីបទពិសោធន៏វិជ្ជមានរបស់គេ។

ជាចុងបញ្ចប់ មេធាវីជំនួយផ្នែកច្បាប់ជាច្រើន ជាពិសេស អ្នកដែលកំពុងធ្វើការយូរមកហើយនៅតាមបណ្តាខេត្តផ្សេងៗ ជួនកាលគេមានអារម្មណ៍ថាធ្វើការតែម្នាក់ឯង នៅក្នុងតួនាទីរបស់ក្នុងការផ្លាស់ប្តូរនូវបទពិសោធន៍មួយចំនួនជាមួយសហភាតារបស់គេ។ លើសពីនេះទៀត អ្នកឆ្លើយសំនួរជាច្រើន ដែលភាគច្រើន គឺជាមន្ត្រីជាន់ខ្ពស់នៅក្នុងអង្គការនីមួយៗ បានមើលឃើញនូវសេចក្តីត្រូវការមួយសំរាប់ការផ្តល់សិទ្ធិអំណាចបន្ថែមទៀតដល់មេធាវី ជាពិសេស ប្រសិនបើពួកគេត្រូវដើរតួនាទីនៅក្នុងការលើកស្ទួយឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងប្រព័ន្ធតុលាការកម្ពុជានាពេលបច្ចុប្បន្ន។ ដោយយកចិត្តទុកដាក់ទៅលើសេចក្តីត្រូវការឱ្យមានកិច្ចសន្ទនានិងការផ្តល់សិទ្ធិអំណាច អ្នកឆ្លើយមួយចំនួនបានស្នើឱ្យមានកិច្ចសហប្រតិបត្តិការឱ្យកាន់តែល្អប្រសើរឡើងនៅក្នុងចំណោមមេធាវីផ្សេងៗ និងអនុញ្ញាតឱ្យមានការផ្លាស់ប្តូរបទពិសោធជាទៀងទាត់នៅក្នុងចំណោមមេធាវីជំនួយផ្នែកច្បាប់នានា។ គួរគត់សំគាល់ថាគំនិតនៃការផ្លាស់ប្តូរបទពិសោធបែបនេះធ្លាប់បានត្រូវគេកាលពីពេលមុនរួចហើយ ប៉ុន្តែគ្រាន់តែត្រូវការឱ្យមានកិច្ចសម្របសម្រួលបន្ថែមទៀត ដើម្បីឱ្យមានលក្ខណៈល្អប្រសើរឡើងដូចការប្រាថ្នាចង់បាន។

## ៣. សេចក្តីសន្និដ្ឋាន

របាយការណ៍នេះ បានផ្តល់ការវាយតម្លៃយ៉ាងសង្ខេបទៅលើវិស័យជំនួយផ្នែកច្បាប់បច្ចុប្បន្ន នៅក្នុងប្រទេសកម្ពុជា។ របាយការណ៍នេះ បានបញ្ជាក់បន្ថែមនូវរបកគំហើញជាច្រើននៃរបាយការណ៍ស្ទង់មតិឆ្នាំ២០០៦ ដែលបង្ហាញថា វិស័យជំនួយផ្នែកច្បាប់ត្រូវការពេលវេលា ប៉ុន្តែវាក៏ត្រូវការឱ្យមានផែនការសំរេចចិត្តបន្ថែមទៀត ដើម្បីធ្វើឱ្យស្ថានភាពបច្ចុប្បន្នល្អប្រសើរឡើង។ បើពុំមានមុខងារត្រឹមត្រូវនៃប្រព័ន្ធជំនួយផ្នែកច្បាប់ទេនោះ ប្រព័ន្ធតុលាការកម្ពុជានឹងនៅតែមិនអាចឱ្យអ្នកដែល

ត្រូវការជំនួយប្រឹក្សាយោបល់ផ្នែកច្បាប់ ទទួលបាននូវសេវាកម្មនេះដោយងាយស្រួល និងពេញលេញ ដែលភាគច្រើន ពួកគេទាំងនោះជាប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះនៅក្នុងប្រទេសនេះ។ កិច្ចសម្ភាសន៍ជាមួយមន្ត្រីជាន់ខ្ពស់នៃអ្នកផ្តល់ជំនួយផ្នែកច្បាប់ទាំងឡាយ សុទ្ធតែបានយល់ស្របទស្សនៈគ្នាទៅលើភាពចាំបាច់នៃសេវាកម្មជំនួយផ្នែកច្បាប់នៅកម្ពុជា ជាជាងការមិនយល់ស្របគ្នា។ ដូចនេះ កំណែទម្រង់ និងការអភិវឌ្ឍណាមួយ នៃវិស័យជំនួយផ្នែកច្បាប់របស់ប្រទេសកម្ពុជា អាចយកតាមទំរង់នៃការគាំទ្រទូទៅរបស់តួអង្គអ្នកផ្តល់ជំនួយផ្នែកច្បាប់ដែលមានស្រាប់បច្ចុប្បន្ន។ ជាងនេះទៅទៀត អ្នកឆ្លើយសំនួរជាច្រើន ក៏បានគូសបញ្ជាក់អំពីការអនុវត្ត ឬបទពិសោធន៍ល្អៗនៅក្នុងប្រទេសមួយចំនួន ជាពិសេស នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលផ្តល់ភស្តុតាងកាន់តែច្រើនថែមទៀតសំរាប់យកមករៀនសូត្រតាម។ សរុបមក យោងតាមយោបល់ដែលផ្តល់ដោយអ្នកឆ្លើយទាំងអស់បង្ហាញថា មិនមាន *គំរូខ្នាតមួយត្រូវគ្រប់គំរូវការទាំងអស់ (one-fit-all model)* សំរាប់ជំនួយផ្នែកច្បាប់ក្នុងប្រទេសកម្ពុជា សំរាប់ពេលអនាគតនោះទេ។ ផ្ទុយទៅវិញ គេបានសង្កត់ធ្ងន់ថា វាចាំបាច់ណាស់ ដើម្បីរួមបញ្ចូលគ្នានូវរចនាសម្ព័ន្ធដែលមានស្រាប់ ជាមួយនឹងវិធីសាស្ត្រថ្មីៗដទៃទៀតប្រកបដោយគំនិតច្នៃប្រឌិត សំរាប់ការផ្តល់សេវាកម្មជំនួយផ្នែកច្បាប់ដល់អ្នកដែលត្រូវការទាំងនោះ។

## កំរងព័ត៌មាន — សមាគមការពារសិទ្ធិមនុស្ស និង អភិវឌ្ឍន៍នៅកម្ពុជា (ADHOC)

**អាស័យដ្ឋានការិយាល័យ :** ផ្ទះលេខ៣ ផ្លូវ១៥៨ ឧកញ៉ាទ្រឿងកាង សង្កាត់បឹងរាំង ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ។

**ទំនាក់ទំនង:** ទូរស័ព្ទ: ៨៥៥-២៣ ៩៩០ ៥៤៤ អ៊ីម៉ែល: adhoc@forum.org.kh គេហទំព័រ: www.adhoc-chra.org

**ចំនួនមេធាវីសរុប:** មេធាវី២នាក់បំរើការងារនៅស្នាក់ការកណ្តាល និងជាអ្នកការពារក្តីលើករណីមួយចំនួន ។

**ចំនួនករណីសរុបដែលបានការពារប្រចាំឆ្នាំ:**

២០០៧: ២៩ ករណី

២០០៨: ៤២ ករណី

២០០៩: ២៤ ករណី

**ចំនួនករណីដែលមេធាវីម្នាក់ៗបានការពារក្នុងមួយឆ្នាំ:**

ប្រមាណពី ១០ ទៅ ១៥ ករណី ក្នុងមួយឆ្នាំ សំរាប់មេធាវីម្នាក់ៗ

**ការិយាល័យតំបន់:**

អាដហុកមានការិយាល័យនៅតាមខេត្ត : បន្ទាយមានជ័យ បាត់ដំបង សៀមរាប ពោធិសាត់ កំពង់ធំ កំពង់ចាម កំពង់ស្ពឺ កំពង់ឆ្នាំង ព្រះសីហនុ កំពត ព្រៃវែង ឧត្តរមានជ័យ កណ្តាល តាកែវ ព្រះវិហារ ស្ទឹងត្រែង រតនះគីរី មណ្ឌលគីរី និង ខេត្តក្រចេះ (ការិយាល័យនៅតាមខេត្ត តែមិនមានមេធាវីប្រចាំការទេ)។

**សេវាកម្មផ្តល់ជំនួយផ្នែកច្បាប់នៅតាមខេត្ត:**

ផ្តល់សេវាកម្មជំនួយផ្នែកច្បាប់តែទៅលើករណីរំលោភសិទ្ធិមនុស្សភាគច្រើន ដែលអាដហុកមានការិយាល័យប៉ុណ្ណោះ ។

**ឯកទេសកម្មជំនាញ:**

អាដហុក គឺជាអង្គការសិទ្ធិមនុស្សក្នុងស្រុកដំបូង ដែលមានសមត្ថភាពផ្លូវច្បាប់ ដោយបានធ្វើការស៊ើបអង្កេត និងអន្តរាគមន៍ លើករណីរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ។ ករណីទាំងនោះ ពាក់ព័ន្ធនឹងអំពើហឹង្សាក្នុងគ្រួសារ រំលោភសេពសន្ថវៈ ការជួញដូរមនុស្ស និង ជួញដូរផ្លូវភេទ ការលែងលះ ការបង្ករបួសស្នាម អំពើមនុស្សឃាត,ការសំលាប់ក្រៅច្បាប់ ការគំរាមកំហែង និង ករណីវិវាទដីធ្លី (ដែលជាមូលហេតុនាំឱ្យមានករណីព្រហ្មទណ្ឌ)។

**ប្រភពមូលនិធិគាំទ្រ:**

EWMI, TAF, NOVIB, DIAKONIA, DANIDA, DCA

**ការផ្លាស់ប្តូរស្ថានភាពថវិកាពីឆ្នាំ២០០៧-២០១០:**

ស្ថានភាពមូលនិធិមានលំនឹងល្អ ពីមួយឆ្នាំ ទៅមួយឆ្នាំ។

ចាប់តាំងពីមានគំរោងជំនួយផ្នែកច្បាប់របស់អាដហុកដែលបានចូលរួមជួយអន្តរាគមន៍ លើករណីទាំងឡាយ ដោយមានការ គាំទ្រពីម្ចាស់មូលនិធិ។

## កំរងព័ត៌មាន — សមាគមមេធាវីឥតព្រំដែនប្រទេសបារាំង (ASF)

**អាស័យដ្ឋានការិយាល័យ:** ផ្ទះលេខ ៧១ សង្កាត់ជ្រោយចង្វា រាជធានីភ្នំពេញ (ការិយាល័យក្រុមមេធាវីឥតព្រំដែនកម្ពុជា) ។

**ទំនាក់ទំនង:** ទូរស័ព្ទ,ទូរសារ: ៨៥៥-២៣ ៧២២ ០៥១ អ៊ីម៉ែល : asf.cambo@hotmailc.om

**ចំនួនមេធាវីសរុប:**

មានមេធាវី ២២នាក់ សំរាប់បំរើការនៅតាមខេត្ត ដែលមានសាលាដំបូងខេត្តនីមួយៗ ។

**ចំនួនករណីសរុបដែលបានការពារប្រចាំឆ្នាំ:**

ជាមធ្យម គិតពី ឆ្នាំ ២០០៦-២០០៨ មេធាវីការពារក្តី មានចំនួនពី ៧២០ករណី ទៅ ១២០០ករណី

**ចំនួនករណីដែលមេធាវីម្នាក់ៗបានការពារក្នុងមួយឆ្នាំ:**

មេធាវីម្នាក់ៗរំពឹងថា នឹងទទួលយក ៣ ករណីធំៗ (ករណីបទឧក្រិដ្ឋ) ឬ១០ករណីតូចៗ (ព្រហ្មទណ្ឌ និងរដ្ឋប្បវេណី)

នៅក្នុង ១ ខែៗ ។

**ការិយាល័យតំបន់:**

មេធាវី២២នាក់ បំរើការនៅតាមខេត្ត ក្នុងនោះ មេធាវី២នាក់ បំរើការនៅខេត្តសៀមរាប និង២នាក់ទៀតនៅខេត្តបាត់ដំបង ។

**សេវាកម្មផ្តល់ជំនួយផ្នែកច្បាប់នៅតាមខេត្ត:**

មិនមាន

**ឯកទេសកម្មជំនាញ:**

ជាបឋមផ្តោតលើករណីព្រហ្មទណ្ឌដែលបានបញ្ជូនដោយសាលាដំបូងខេត្ត និងករណីមួយចំនួនតូច ជាករណីរដ្ឋប្បវេណី ។

**ប្រភពមូលនិធិគាំទ្រ:**

គំរោងផែនការនេះគឺទទួលបានការគាំទ្រពីភ្នាក់ងារអភិវឌ្ឍន៍បារាំង (**AFD**) និង គ្រប់គ្រងដោយក្រុមមេធាវីឥតព្រំដែនបារាំង (ជិត៣ឆ្នាំ) ។

**ការផ្លាស់ប្តូរស្ថានភាពថវិកាពីឆ្នាំ២០០៧-២០១០:**

គំរោងថ្មីមួយចាប់តាំងពីខែ មីនា ឆ្នាំ២០១០ ដែលបានផ្តល់មូលនិធិតាមរយ: **AFD**

## កំរងព័ត៌មាន — នាយកដ្ឋានការពារជនក្រីក្រ នៃ គណៈមេធាវីកម្ពុជា (BACK-LAD)

**អាស័យដ្ឋានការិយាល័យ:** ផ្ទះលេខ ១០-១១ Eo ផ្លូវ១៨០ ( ផ្លូវកាកបាទក្រហម ) រាជធានីភ្នំពេញ ។

**ទំនាក់ទំនង:** ទូរស័ព្ទ/ទូរសារ: ៨៩៥-២៣ ២២០ ២៣៧, អ៊ីម៉ែល: info@bakc.org.kh, គេហទំព័រ: www.bakc.org.kh

**ចំនួនមេធាវីសរុប:**

មេធាវី ១៥នាក់ ( បំរើការពេញម៉ោងចំនួន ៨នាក់ និង ចំនួន ៧នាក់ បំរើការមិនពេញម៉ោង)

**ចំនួនករណីសរុបដែលបានការពារប្រចាំឆ្នាំ:**

ឆ្នាំ ២០០៩: ៨០២ ករណីថ្មី ( បញ្ចប់៣០៨ករណី)

ឆ្នាំ ២០១០ ( ចាប់ពីខែវិច្ឆិកា): ៨០៦ ករណី ( បញ្ចប់៣៧៥ករណី)

**ចំនួនករណីដែលមេធាវីម្នាក់ៗបានការពារក្នុងមួយឆ្នាំ:**

មិនមាន

**ការិយាល័យតំបន់ :**

មិនមាន

**សេវាកម្មផ្តល់ជំនួយផ្នែកច្បាប់នៅតាមខេត្ត:**

ផ្តោតលើករណីទូទាំងប្រទេស ដោយយោងតាមការស្នើសុំ

**ឯកទេសកម្មជំនាញ:**

ផ្តល់សេវាកម្មជំនួយផ្នែកច្បាប់ទូទៅ ប៉ុន្តែភាគច្រើនផ្តោតទៅលើករណីព្រហ្មទណ្ឌ

**ប្រភពមូលនិធិគាំទ្រ:**

- ជំនួយរបស់វិទ្យាស្ថានគ្រប់គ្រងបស៊ឹម-បូពា EWMI

- រាជរដ្ឋាភិបាលកម្ពុជា ( ប្រមាណ១០០លានរៀល/ ២៥,០០០ ដុល្លារ ក្នុងមួយឆ្នាំ) ។

**ការផ្លាស់ប្តូរស្ថានភាពថវិកាពីឆ្នាំ២០០៧-២០១០:**

មិនមានច្រើនទេ

## កំរងព័ត៌មាន — ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP)

**ទីតាំងការិយាល័យ:** ផ្ទះលេខ៨0F ផ្លូវលេខ២៦៥ សង្កាត់ទឹកល្អក់៣ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ។

**ទំនាក់ទំនង:** ទូរស័ព្ទលេខ: ៨៥៥-២៣ ៨៨០ ៩០៧ អ៊ីម៉ែល:cdp@cdpcambodia.org, www.cdpcambodia.org

**ចំនួនមេធាវីសរុប:**

មេធាវី២២នាក់ : ការិយាល័យខេត្តបាត់ដំបង (មេធាវីម្នាក់) ការិយាល័យខេត្តសៀមរាប (មេធាវី២នាក់) និង ការិយាល័យភ្នំពេញ (១៩នាក់ រួមទាំងនាយកប្រតិបត្តិ និងប្រធាននៃជំនួយការបច្ចេកទេស)

**ចំនួនករណីសរុបដែលបានការពារប្រចាំឆ្នាំ:**

ឆ្នាំ ២០០៧ : ៨៨៨ ករណីថ្មី, ឆ្នាំ ២០០៨ : ៦៨៧ ករណីថ្មី, ឆ្នាំ ២០០៩ : ៥៩៣ ករណីថ្មី

**ចំនួនករណីដែលមេធាវីម្នាក់ៗបានការពារក្នុងមួយឆ្នាំ:**

ជាមធ្យម: ពី ៣០ករណី ទៅ ៥០ករណីថ្មីក្នុងមេធាវីម្នាក់ៗ បន្ថែមលើករណីមិនទាន់បញ្ចប់ ។

**ការិយាល័យតំបន់ :**

ខេត្តបាត់ដំបង និងសៀមរាប (២០១០) ចំណែកឯ ការិយាល័យផ្សេងទៀត ដែលទើបបិទមាន នៅ ខេត្តកំពង់ចាម ក្រចេះ និងកំពង់ធំ ។

**សេវាកម្មផ្តល់ជំនួយផ្នែកច្បាប់នៅតាមខេត្ត :**

ផ្តោតទៅលើករណីទូទាំងប្រទេសដែលត្រូវនឹងគោលការណ៍របស់អង្គការ (កូនក្តីដែលមកពឹងពាក់ផ្ទាល់ ឬបញ្ជូនដោយអង្គការផ្សេង) ។

**ឯកទេសកម្មជំនាញ:**

ផ្តល់សេវាកម្មជំនួយផ្នែកច្បាប់ ទាំងករណីព្រហ្មទណ្ឌ និងករណីរដ្ឋប្បវេណី ដល់អ្នកក្រីក្រ និងជនងាយរងគ្រោះ ឬ ជាក្រុម ។ ពិគ្រោះយោបល់ លើករណីទាក់ទងនឹងការរំលោភសិទ្ធិមនុស្សដូចជា ការចាប់ឃុំខ្លួនខុសច្បាប់ ការរំលោភសេពសន្ថវៈ (ទាំងជនរងគ្រោះ និងជនជាប់ចោទ ទោះបីជាយ៉ាងណាក៏ដោយ អ្នកដែលមកសុំជំនួយមុន នឹងផ្តល់ជាអាទិភាព ។

-ជនរងគ្រោះដោយអំពើហឹង្សា (ជំងឺអេដស៍/ហ៊ីវ), ការវាយប្រហារដោយទឹកអាស៊ីដ

-ហឹង្សាក្នុងគ្រួសារ (ជាពិសេសហឹង្សាប្រឆាំងស្ត្រី)

-ការជួញដូរមនុស្ស ,ការជួញដូរផ្លូវភេទ ប្រឆាំងនឹងស្ត្រី និងកុមារ

-ជនរងគ្រោះដោយអំពើហឹង្សាផ្លូវភេទ នៅក្នុងរបបខ្មែរក្រហម និង ជនរងគ្រោះដោយអំពើទារុណកម្ម និង

-វិវាទដីធ្លី ពាក់ព័ន្ធនឹងសិទ្ធិដីធ្លី ។

**ប្រភពមូលនិធិគាំទ្រ:**

Forum Syd, EWMI, DCA, DANIDA, EU

**ការផ្លាស់ប្តូរស្ថានភាពថវិកាពីឆ្នាំ២០០៧-២០១០:**

ចាប់តាំងពីឆ្នាំ ២០០៩មូលនិធិបានថយចុះប្រមាណ ៣៥ % នៃថវិកាទាំងអស់ ។

## កំរងព័ត៌មាន — មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ (CLEC)

**ទីតាំងការិយាល័យ:** ផ្ទះលេខ៥៤ ផ្លូវលេខ៣០៦ សង្កាត់បឹងកេងកង១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ។

**ទំនាក់ទំនង:** ទូរស័ព្ទលេខ: ៨៥៥-២៣ ២១១ ៧២៣ អ៊ីម៉ែល: admin@clec.org.kh គេហទំព័រ: www.clec.org.kh

**ចំនួនមេធាវីសរុប:** មេធាវី ៦ នាក់ (២០១០) ហើយ មេធាវីទាំងអស់ប្រចាំការនៅភ្នំពេញ ។

**ចំនួនករណីសរុបដែលបានការពារប្រចាំឆ្នាំ:**

ផ្តោតលើករណីដែលជាករណីលេចធ្លោសំខាន់ៗ (high profile cases) ដូចជាវិវាទដីធ្លី ពាក់ព័ន្ធនឹងជនរងគ្រោះចាប់ពី ៥០ គ្រួសារឡើងទៅ។

ជាមធ្យម CLEC កាន់ករណីចំនួន៩ក្នុងមួយឆ្នាំ, ប្រឹក្សាយោបល់ និងការពារក្តីសកម្មជនដីធ្លីចំនួន៤-៥ករណី ក្នុងមួយឆ្នាំៗ ។

**ចំនួនករណីដែលមេធាវីម្នាក់ៗបានការពារក្នុងមួយឆ្នាំ:**

មេធាវីម្នាក់ៗ កាន់ចំនួន ៤ករណី ក្នុងមួយឆ្នាំៗ ទោះបីជាយ៉ាងណាមេធាវីទាំងអស់ធ្វើការងារជាក្រុម លើករណីធំៗ មានមេធាវី២ដែលធ្វើការដោយឡែកទៅលើបញ្ហាវិវាទការងារ, ការពារសកម្មជនសហជីព និងផ្តល់ការប្រឹក្សាយោបល់ជាទូទៅ។ មេធាវីម្នាក់ៗ ចំណាយពេល៤០-៥០% ទៅលើការពិគ្រោះយោបល់ផ្លូវច្បាប់ ព្រមទាំងចុះសិក្សាដល់កន្លែងវិវាទ ដើម្បីស្រាវជ្រាវរកការពិត និងធ្វើការវិភាគផ្លូវច្បាប់ ជាដើម។

**ការិយាល័យតំបន់ :**

មិនមានបុគ្គលិកជាមេធាវីប្រចាំការនៅការិយាល័យតាមបណ្តាខេត្តជាក់លាក់ទេ ប៉ុន្តែទោះជាយ៉ាងណា CLEC មានបុគ្គលិកជំនាញផ្នែកច្បាប់ពីការិយាល័យភ្នំពេញនឹងចុះទៅបំពេញការងារជាទៀងទាត់ នៅខេត្តតាមតម្រូវការជាក់ស្តែង។

តាំងពី ឆ្នាំ២០០៧ CLEC មានការិយាល័យពីរទៀត នៅខេត្តមណ្ឌលគីរី និង រតនគីរី ដែលមានបុគ្គលិកគំរោងចំនួន ២ នាក់ ។

**សេវាកម្មផ្តល់ជំនួយផ្នែកច្បាប់នៅតាមខេត្ត :**

CLEC ផ្តោតយកខេត្តមណ្ឌលគីរី និងរតនគីរី ជាខេត្តអាទិភាព ដោយពុំមានការកំណត់ទៅលើតំបន់ណាមួយជាក់លាក់ទេ គឺអាស្រ័យលើករណី ។ សកម្មភាពជំនួយផ្លូវច្បាប់ពីមុន បានគ្របដណ្តប់លើតំបន់មួយចំនួន រួមមាន: កោះកុង ភ្នំពេញ ក្រចេះ បន្ទាយមានជ័យ ឧត្តរមានជ័យ និង ខេត្តព្រះវិហារ ។

**ឯកទេសកម្មជំនាញ:**

-ករណីដីធ្លីដែលប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ (ប៉ះពាល់ចាប់ពី ១០គ្រួសារ ឬរាប់រយគ្រួសារ ។
-ផ្តល់ការប្រឹក្សាយោបល់ដល់ចុងចោទក្នុងរឿងព្រហ្មទណ្ឌ ជាពិសេសគឺ សកម្មជនការពារដីធ្លី
-ពិគ្រោះយោបល់ផ្នែកច្បាប់ ជាពិសេសនៅតំបន់ដែល CLEC មិនអាចធ្វើជាតំណាងការពារក្តីបានពេញលេញ
-ករណីទាក់ទិននឹងច្បាប់ការងារ (វិវាទការងារ)
-ករណីមួយចំនួនពាក់ព័ន្ធនឹងជនជាតិដើមភាគតិច

**ប្រភពមូលនិធិគាំទ្រ:**

EED, ICCO, EED, ICCO, TAF/USAID

## កំរងព័ត៌មាន — អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC)

**ទីតាំងការិយាល័យ:** ផ្ទះលេខ៤២ F ផ្លូវលេខ ៤៨៨ សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ។

**ទំនាក់ទំនង:** ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៩៨៧ ១៥៨ អ៊ីម៉ែល: cwccpnp@cwcc.org.kh

គេហទំព័រ: www.cwcc.org.kh

**ចំនួនមេធាវីសរុប:** នៅឆ្នាំ ២០១០ CWCC មានមេធាវីចំនួន ៤ នាក់បំរើការ និង បុគ្គលិកជំនាញច្បាប់ចំនួន ៤នាក់។

**ចំនួនករណីសរុបដែលបានការពារប្រចាំឆ្នាំ:**

២០១០ (ខែមករា ដល់មិថុនា) : ១២៣ ករណី ក្នុងនោះ ៨៦ករណីបានបញ្ជូនទៅជំរះ ករណីទាំង៤១២ករណីមិនទាន់បញ្ចប់

២០០៩ : ២៧០ករណី (ខែមករា ដល់ ខែធ្នូ) ១៦៩ ករណី បានបញ្ជូនទៅជំរះ

២០០៨: ១៦៤ករណី បានបញ្ជូនទៅជំរះ

២០០៧ : ១៣៣ ករណី បានបញ្ជូនទៅជំរះ

**ចំនួនករណីដែលមេធាវីម្នាក់ៗបានការពារក្នុងមួយឆ្នាំ:**

មេធាវីម្នាក់ៗ កាន់ចំនួន ៥០ករណី ក្នុងមួយឆ្នាំៗ

**ការិយាល័យតំបន់:**

CWCC មានមេធាវី នៅការិយាល័យនៅតាមខេត្ត/ក្រុង ដូចជា:

- ភ្នំពេញ មានមេធាវីចំនួន ២នាក់
- ខេត្តបន្ទាយមានជ័យ មានមេធាវីម្នាក់ និង
- ខេត្តសៀមរាប មានមេធាវីម្នាក់

**សេវាកម្មផ្តល់ជំនួយផ្នែកច្បាប់នៅតាមខេត្ត:**

- ភ្នំពេញ (គ្របដណ្តប់រួមទាំង ខេត្តកណ្តាល)
- ខេត្តបន្ទាយមានជ័យ (គ្របដណ្តប់ទៅលើខេត្តបាត់ដំបង និង ប៉ៃលិន)
- ខេត្តសៀមរាប (គ្របដណ្តប់ទាំងខេត្តឧត្តរមានជ័យ)

CWCC ក៏ផ្តល់សេវាកម្មជំនួយផ្នែកច្បាប់មួយចំនួន (មានកំរិត) សំរាប់ករណីកើតឡើងនៅក្រៅប្រទេសផងដែរ។

**ឯកទេសកម្មជំនាញ:**

CWCC ធ្វើជាតំណាង និងការពារក្តីដល់ស្ត្រីគ្រប់វ័យ (មិនគិតពីអាយុ) ។

- គោលការណ៍ការងារផ្តោតជាសំខាន់គឺ ករណីព្រហ្មទណ្ឌ និងរដ្ឋប្បវេណី (សំរាប់ជនរងគ្រោះជាស្ត្រី និងចុងចោទជាស្ត្រី )
- ករណីរំលោភសេពសន្ថវៈ
- ករណីជួញដូរ (ការជួញដូរផ្លូវភេទ និងជួញដូរកំលាំងពលកម្ម ) និងការធ្វើអាជីវកម្មផ្លូវភេទ ។

**ប្រភពមូលនិធិគាំទ្រ:**

DCA, Terres des Hommes, UNICEF

## កំរងព័ត៌មាន — អង្គការស្ពានយុត្តិធម៌អន្តរជាតិ (IBJ)

**ទីតាំងការិយាល័យ:** ផ្ទះលេខ៤១ ផ្លូវលេខ ៤៨៨ សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ។

**ទំនាក់ទំនង:** ទូរស័ព្ទ: ៨៥៥-២៣ ៩៨៧ ៣១៣ អ៊ីម៉ែល: ibj_vandeth@online.com.kh គេហទំព័រ: www.ibj.org

**ចំនួនមេធាវីសរុប:**

នៅឆ្នាំ ២០១០ IBJ មានមេធាវីសរុបទាំងអស់ចំនួន ៦ នាក់។

**ចំនួនករណីសរុបដែលបានការពារប្រចាំឆ្នាំ:**

IBJ បានក្លាយខ្លួនជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកឯករាជ្យ និងចាប់ផ្តើមការងារការពារក្តីចាប់ពីពេលបង្កើតរហូតដល់ខែសីហា ឆ្នាំ ២០១០ ដែលមានសរុបទាំងអស់ចំនួនជាង ៩០០ ករណី (មិនមានចំនួនប្រចាំទេ) ។ ជាមធ្យម គឺ:

២០០៩ : ប្រហែល ៣២០ ករណីថ្មី

**ចំនួនករណីដែលមេធាវីម្នាក់ៗបានការពារក្នុងមួយឆ្នាំ:**

មេធាវីម្នាក់ៗ កាន់ចំនួនប្រមាណ ១៥០ករណី ក្នុងមួយឆ្នាំៗ

**ការិយាល័យតំបន់:**

IBJ មាការិយាល័យប្រចាំការនៅ:

- ភ្នំពេញ (មានមេធាវី សំរាប់ខេត្តកណ្តាល និងកំពង់ស្ពឺ)
- ខេត្តតាកែវ (មានមេធាវីម្នាក់ សំរាប់ខេត្តតាកែវ និងខេត្តកំពត)
- ខេត្តពោធិសាត់ (មានមេធាវីម្នាក់ សំរាប់ខេត្តពោធិសាត់ និងកំពង់ឆ្នាំង)
- ខេត្តព្រៃវែង (មានមេធាវីម្នាក់ សំរាប់ព្រៃវែង និងស្វាយរៀង)

**សេវាកម្មផ្តល់ជំនួយផ្នែកច្បាប់នៅតាមខេត្ត:**

សេវាកម្មជំនួយផ្នែកច្បាប់អាចគ្រប់ដណ្តប់តែនៅក្នុងខេត្តដែលបានរៀបរាប់ខាងតែប៉ុណ្ណោះ តាមរយៈការិយាល័យតំបន់។

**ឯកទេសកម្មជំនាញ:**

ផ្តោតលើ (១) ករណីព្រហ្មទណ្ឌ, (២) ជនជាប់ចោទ (ដែលមានលក្ខណៈខុសពីអង្គការដទៃទៀតដែលផ្តោតលើទាំងជនរងគ្រោះនៃករណីរំលោភសិទ្ធិមនុស្សទូទៅ):

- ការពារក្តីឱ្យជនជាប់ចោទ ដែលជាជនក្រីក្រ និងជាករណីធំៗ
- ផ្តល់វគ្គបណ្តុះបណ្តាលបង្កើនការយល់ដឹងផ្នែកច្បាប់ដល់មន្ត្រីយុត្តិធម៌ ព្រះរាជអាជ្ញា និងមេធាវី។

**ប្រភពមូលនិធិគាំទ្រ:**

- WISE, EuropeAID និង
- ម្ចាស់ជំនួយរបស់ IBJ នៅឯស្នាក់ការកណ្តាល នៅទីក្រុង ហ្សឺណែវ ប្រសិនបើចាំបាច់ ។

## កំរងព័ត៌មាន — អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC)

**ទីតាំងការិយាល័យ:** ផ្ទះលេខ៩១ ផ្លូវលេខ៦០៨ សង្កាត់ បឹងកក់២ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ។

**ទំនាក់ទំនង:** ទូរស័ព្ទលេខ: ៨៥៥-២៣ ៨៨៣ ៩១៤ ,៨៣៣ ៩២៤ អ៊ីម៉ែល:lac@lac.org.kh គេហទំព័រ: www.lac.org.kh

**ចំនួនមេធាវីសរុប:** នៅឆ្នាំ២០១០ មានមេធាវី២៧នាក់ និង បុគ្គលិកមិនមែនជាមេធាវី ចំនួន៩១នាក់។

**ចំនួនករណីសរុបដែលបានការពារប្រចាំឆ្នាំ:**

២០០៩ : ១,៦២៨ ករណីថ្មី, ២០០៨: ១,២៩១ ករណីថ្មី, ២០០៧: ១,៤៨១ ករណីថ្មី

**ចំនួនករណីដែលមេធាវីម្នាក់ៗបានការពារក្នុងមួយឆ្នាំ:**

ជាគោលការណ៍របស់អង្គការ មេធាវីម្នាក់ជាមធ្យមកាន់ករណី ៤៥ករណី ក្នុង១ឆ្នាំ (៣-៤ករណី ក្នុង១ខែ ក្នុងមេធាវីម្នាក់) ។

**ការិយាល័យតំបន់ :**

នៅត្រឹមខែសីហា ឆ្នាំ២០១០ LAC មានការិយាល័យនៅ:

ខេត្តកណ្តាល (តុលាការគំរូ), កំពង់ចាម (គ្រប់ដណ្តប់ការងារលើខេត្តព្រៃវែង និងខេត្តកំពង់ធំ) រតនះគីរី និង សៀមរាប ។

**សេវាកម្មផ្តល់ជំនួយផ្នែកច្បាប់នៅតាមខេត្ត :**

ការផ្តល់សេវាកម្មជំនួយផ្នែកច្បាប់ ដោយផ្តោតទៅលើតាមតំបន់ខាងលើ ។

**ឯកទេសកម្មជំនាញ:**

សេវាកម្មជំនួយផ្នែកច្បាប់ទូទៅ, កម្មវិធីយុត្តិធម៌ស្ត្រី, កម្មវិធីយុត្តិធម៌កុមារ, កម្មវិធីដីធ្លី, និងគំរោងការពារក្តីឱ្យជនរងគ្រោះនៅចំពោះមុខសាលាក្តីខ្មែរក្រហម

**ប្រភពមូលនិធិគាំទ្រ:**

- កម្មវិធីជំនួយផ្នែកច្បាប់ទូទៅ: វិទ្យាស្ថានគ្រប់គ្រងបស្ចឹម-បូព៌ា (EWMI )

-មានសញ្ញានៃកង្វះថវិកា ក្រោយពី ណូវីប (Novib )បញ្ឈប់ការផ្តល់ថវិកា ក្នុងឆ្នាំ ២០០៩

(មានការបិទការិយាល័យចំនួន៣ និងបញ្ឈប់មេធាវី ចំនួន ១៣នាក់) ។

-កម្មវិធីសាលាក្តីខ្មែរក្រហម: គាំទ្រមូលនិធិដោយអង្គការសេវាកម្មអភិវឌ្ឍន៍អាល្លឺម៉ង់ (DED-Cambodia)

កម្មវិធីយុត្តិធម៌ស្ត្រី: CCJAP, GTZ និង AusAID

- កម្មវិធីយុត្តិធម៌កុមារ: UNICEF, អង្គការ Every child និងអង្គការផ្សេងទៀត

- កម្មវិធីដីធ្លី: សំរាប់ករណីលេចធ្លោរ គាំទ្រដោយវិទ្យាស្ថានគ្រប់គ្រងបស្ចឹម-បូព៌ា (EWMI)

## កំរងព័ត៌មាន — អង្គការសម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្សលីកាដូ (LICADHO)

**ទីតាំងការិយាល័យ:** ផ្ទះលេខ១៦ ផ្លូវលេខ៩៩ សង្កាត់ បឹងត្របែក ខ័ណ្ឌចំការមន រាជធានីភ្នំពេញ។

**ទំនាក់ទំនង:** ទូរស័ព្ទ: ៨៩៥-២៣ ៧២៧ ១០២ អ៊ីម៉ែល: contact@licahdo-cambodia.org

គេហទំព័រ: www.licahdo-cambodia.org

**ចំនួនមេធាវីសរុប:**

នៅឆ្នាំ២០១០ LICADHO មានមេធាវីចំនួន ៥ នាក់ ។

**ចំនួនករណីសរុបដែលបានការពារប្រចាំឆ្នាំ:**

ធ្វើការទៅលើករណី ប្រមាណ៤០-៥០ករណី ក្នុងមួយឆ្នាំ។

២០១០ ( មកដល់ខែសីហា): ២២ករណី, ២០០៩ : ៥២ករណី, ២០០៨: ៣៨ ករណី, ២០០៧: ៣៦ ករណី

**ចំនួនករណីដែលមេធាវីម្នាក់ៗបានការពារក្នុងមួយឆ្នាំ:**

LICADHO មានគោលការណ៍ផ្ទៃក្នុងច្បាស់លាស់កំណត់ថា មេធាវីម្នាក់ជាមធ្យមកាន់ករណី មិនលើសពី១៥-២០ ករណី ក្នុង១ឆ្នាំ។

**ការិយាល័យតំបន់:**

LICADHO មានការិយាល័យនៅតាមបណ្តាខេត្ត: បន្ទាយមានជ័យ បាត់ដំបង សៀមរាប ពោធិសាត់ កំពង់ធំ កំពង់ចាម កំពង់ស្ពឺ កំពង់ឆ្នាំង ព្រះសីហនុ កំពត ស្វាយរៀង ( មានតែការិយាល័យខេត្ត តែមិនមានមេធាវីប្រចាំការនៅខេត្តនោះទេ) ។

**សេវាកម្មផ្តល់ជំនួយផ្នែកច្បាប់នៅតាមខេត្ត :**

-ការផ្តល់សេវាកម្មជំនួយផ្នែកច្បាប់ ភាគច្រើនចំពោះករណី ដែល LICADHO មានការិយាល័យនៅតាមតំបន់នីមួយៗ ខាងលើ។

**ឯកទេសកម្មជំនាញ:**

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សក្នុងស្រុកដំបូងគេ ដែលមានសមត្ថភាពផ្លូវច្បាប់ ។

គោលការណ៍ផ្តោតលើការការពារជនរងគ្រោះដោយសារការរំលោភសិទ្ធិមនុស្ស ដូចជា: បញ្ហាដីធ្លី, សិទ្ធិមនុស្សទូទៅ, រំលោភសេពសន្ទវៈ, ហឹង្សាក្នុងគ្រួសារ និងការជួញដូរ ។

**ប្រភពមូលនិធិគាំទ្រ:**

ថវិកាសំរាប់គាំទ្រកម្មវិធីការពារក្តីរបស់មេធាវី គឺបានមកពី TAF

## កំរងព័ត៌មាន — អង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី (LSCW)

**ទីតាំងការិយាល័យ:** ផ្ទះលេខ ១៣២E-F, ផ្លូវលេខ ១៣៥ សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ។

**ទំនាក់ទំនង:** ទូរស័ព្ទលេខ: ៨៥៥-២៣ ២២០ ៦២៦ អ៊ីម៉ែល: info@lscw.org គេហទំព័រ: www.lscw.org

**ចំនួនមេធាវីសរុប:**

នៅឆ្នាំ២០១០ LSCW មានមេធាវី៦នាក់ ។

**ចំនួនករណីសរុបដែលបានការពារប្រចាំឆ្នាំ:**

LSCW ធ្វើការទៅលើករណី ប្រមាណ ៣០០ករណី ក្នុងឆ្នាំ ២០១០។

**ចំនួនករណីដែលមេធាវីម្នាក់ៗបានការពារក្នុងមួយឆ្នាំ:**

មេធាវីម្នាក់អាចការពារក្តីប្រហែល ១០០ករណី ក្នុង១ឆ្នាំអាស្រ័យតាមការជាក់ស្តែង និងភាពមមាញឹករបស់មេធាវីម្នាក់ៗ។

**ការិយាល័យតំបន់ :**

-ការិយាល័យភ្នំពេញ (មានមេធាវី ៥នាក់)

-ការិយាល័យកោះកុង (មានមេធាវីម្នាក់)

-ការិយាល័យកំពង់ចាម

**សេវាកម្មផ្តល់ជំនួយផ្នែកច្បាប់នៅតាមខេត្ត :**

ការផ្តល់សេវាកម្មជំនួយផ្នែកច្បាប់ ផ្តោតទៅលើករណីនៅខេត្តកណ្តាល កំពង់ស្ពឺ តាកែវ កំពត កំពង់ធំ កំពង់ចាម ព្រៃវែង និង កោះកុង។

**ឯកទេសកម្មជំនាញ:**

ធ្វើជាតំណាងការពារក្តីសំរាប់ស្ត្រី និងកុមារ (កុមារអាយុក្រោម១៥ឆ្នាំ) ដោយផ្តោតលើ:

-ករណីលែងលះ (សំរាប់រឿងរដ្ឋប្បវេណី)

-ករណីរំលោភសេពសន្ថវ : អំពើជួញដូរ ហិង្សាក្នុងគ្រួសារ និងអំពើបង្ករបួសស្នាមទាក់ទិននឹងករណីព្រហ្មទណ្ឌ

**ប្រភពមូលនិធិគាំទ្រ:**

EWMI, COSECM, CCJAP, TAF

**ការផ្លាស់ប្តូរស្ថានភាពថវិកាពីឆ្នាំ២០០៧-២០១០:**

ឆ្នាំ ២០០៧ ដល់ ២០១០ ស្ថានភាពនៃស្ថេរភាពថវិកាមានការធ្លាក់ចុះ សំរាប់ជំនួយផ្នែកច្បាប់។

## កំរងព័ត៌មាន — អង្គការការពារយុត្តិធម៌កុមារ (PJJ)

**ទីតាំងការិយាល័យ:** ផ្ទះលេខ ៣៦ ផ្លូវលេខ៩៩ សង្កាត់បឹងត្របែក ខ័ណ្ឌចំការមន រាជធានីភ្នំពេញ។

**ទំនាក់ទំនង:** ទូរស័ព្ទលេខ: ៨៥៥-២៣ ៧២៦ ៤៤៦ អ៊ីម៉ែល: pjjcambodia@clickmail.com.kh

គេហទំព័រ: www.pjj.org.kh

**ចំនួនមេធាវីសរុប:**

នៅឆ្នាំ២០១០ PJJ មានមេធាវីចំនួន ៤នាក់ (រួមទាំង នាយិការបស់អង្គការ ផងដែរ)

**ចំនួនករណីសរុបដែលបានការពារប្រចាំឆ្នាំ:**

២០០៧ និង ២០០៨: ករណីប្រចាំឆ្នាំប្រមាណ២០០ ករណី, ២០០៩ : ៣៩៣ ករណី

**ចំនួនករណីដែលមេធាវីម្នាក់ៗបានការពារក្នុងមួយឆ្នាំ:**

ជាការប៉ាន់ប្រមាណ នៅក្នុងឆ្នាំ ២០០៧-២០០៨ មេធាវីម្នាក់ការពារក្តីចំនួន ៦០ ករណី ក្នុង ១ឆ្នាំ។

ស្ថិតិនេះបញ្ជាក់ឱ្យឃើញនូវការថយចុះ ពី១៨-១៩ ករណី ក្នុងឆ្នាំ ២០១០ មូលហេតុដោយសារវិបត្តិថវិកា ។

**ការិយាល័យតំបន់ :**

នៅឆ្នាំ ២០១០ PJJ ពុំមានការិយាល័យនៅតាមខេត្តទេ។

២០០៧-២០០៩ : មានការិយាល័យនៅខេត្ត: បាត់ដំបង បន្ទាយមានជ័យ រតនៈគីរី និងសៀមរាប។

**សេវាកម្មផ្តល់ជំនួយផ្នែកច្បាប់នៅតាមខេត្ត:**

បច្ចុប្បន្ននេះការផ្តល់សេវាកម្មជំនួយផ្នែកច្បាប់ ផ្តោតលើករណីនៅភ្នំពេញ និងករណី២-៣ ពីខាងក្រៅប៉ុណ្ណោះ។

**ឯកទេសកម្មជំនាញ:**

អនីតិជន (អាយុក្រោម១៨ឆ្នាំ) ដោយធ្វើការការពារទាំងជនរងគ្រោះ និងជនជាប់ចោទ ។ ភាគច្រើនផ្តោតលើករណីរំលោភសេពសន្ថវៈ។

**ប្រភពមូលនិធិគាំទ្រ:**

អង្គការ UNICEF (ថវិការហូតដល់ខែ ធ្នូ ២០១០), SKN (រហូតដល់ចុងឆ្នាំ ២០១០) KOIS

**ការផ្លាស់ប្តូរស្ថានភាពថវិកាពីឆ្នាំ២០០៧-២០១០:**

ពីឆ្នាំ ២០០៧-២០០៩ កំរិតនៃការគាំទ្រថវិកាល្អប្រសើរ ដោយបានការឧបត្ថម្ភពី EU, SKN, KIA, anestvad, KOIS និង UNICEF។ ក្នុងឆ្នាំ ២០១០ មានតែម្ចាស់មូលនិធិធំៗពីរ នៅបន្តគាំទ្រ ដែលជាសញ្ញានៃការថយចុះថវិកាប្រមាណ ៨០%។